ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៤១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ឯកសណ្ឋានបំពេញការងាររបស់មន្ត្រីរាជការស៊ីវិលនៅទីស្តីការក្រសួងមហាផ្ទៃ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

*****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៧៥ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០០/០៧៦ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌលេខាធិការរដ្ឋបាលក្រសួងមហាផ្ទៃ

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៧៣ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០១/០៤៩ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ២០០១ ស្តីពីសញ្ញាស័ក្តិ និងឯកសណ្ឋានមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ និងក្របខ័ណ្ឌមន្ត្រីក្រមការរបស់ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៨២ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង
- បានឃើញអនុក្រឹត្យលេខ ១៨៣ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលខណ្ឌ នៃរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ ១៨៤ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក
- បានឃើញអនុក្រឹត្យលេខ ១៩៣ អនក្រ.បក ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការប្រគល់មុខងារគ្រប់គ្រង និងផ្តល់សេវាសុខាភិបាលទៅឱ្យរដ្ឋបាលរាជធានី ខេត្ត
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

# សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .—**

អនុក្រឹត្យនេះ មានគោលបំណងកំណត់អំពីឯកសណ្ឋានការងារ មួក សញ្ញាស័ក្តិស្មា សញ្ញាសម្គាល់ និងស្លាកឈ្មោះរបស់មន្ត្រីរាជការស៊ីវិល តាមប្រភេទឋានន្តរស័ក្តិ និងក្របខ័ណ្ឌនីមួយៗ សម្រាប់ស្លៀកពាក់ក្នុងពេលបំពេញការងារប្រចាំថ្ងៃ បេសកកម្ម កិច្ចប្រជុំ សិក្ខាសាលា សន្និបាត និងពិធីផ្សេងៗ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងារ តម្លាភាព គណនេយ្យភាព និងការទទួលខុសត្រូវក្នុងការអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួន ។

**មាត្រា ២ .—**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះមន្ត្រីរាជការស៊ីវិល ដែលបម្រើការងារនៅទីស្តីការក្រសួងមហាផ្ទៃ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ។

## ជំពូកទី២
## ឯកសណ្ឋាន

**មាត្រា ៣ .—**

ឯកសណ្ឋានការងារសម្រាប់មន្ត្រីរាជការស៊ីវិល បម្រើការងារនៅទីស្តីការក្រសួងមហាផ្ទៃ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវស្លៀកពាក់ទៅតាមប្រភេទក្របខ័ណ្ឌ **ក** ក្របខ័ណ្ឌ **ខ** និងក្របខ័ណ្ឌ **គ** ។

## ផ្នែកទី១
## ឯកសណ្ឋានការងារសម្រាប់មន្ត្រីក្របខ័ណ្ឌប្រភេទ ក

**មាត្រា ៤.-**

ឯកសណ្ឋានការងារសម្រាប់មន្ត្រីក្របខ័ណ្ឌប្រភេទ **ក** ដែលបម្រើការងារនៅទីស្តីការក្រសួងមហាផ្ទៃ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានកំណត់ដូចខាងក្រោម ៖

**១-ចំពោះបុរស**

អាវសឺមី និងអាវសាហារីយ៉ែន តេហ្គាលពណ៌សូកូឡាស្រាល និងខោជើងវែងពណ៌ដូចមានរូបភាពក្នុងឧបសម្ព័ន្ធទី១ និងឧបសម្ព័ន្ធទី២ ។

**ក-អាវសម្រាប់បំពេញការងារប្រចាំថ្ងៃ និងបេសកកម្ម ៖**

-អាវសឺមីដៃវែង កឧប មានប៉ូលស្មាទាំងសងខាង ភ្ជាប់ដោយឡេវពណ៌ដូចពណ៌អាវ មិនជីបស្មា មិនជីបខ្នង ផែកចំហៀងសងខាង មានឡេវមុខចំនួនប្រាំគ្រាប់ពណ៌ដូចពណ៌អាវ ។ នៅចុងដៃអាវមានឡេវសម្រាប់បិទពណ៌ ដូចពណ៌អាវចំនួនពីរគ្រាប់ ។ អាវនេះ មានហោប៉ៅដេរប៉ះខាងលើចំនួនពីរដែលដេរបត់ផ្នត់កណ្តាល មានគម្របរាងស្លឹកពោធិ៍ ចោះរន្ធសម្រាប់ដាក់ឡេវ ដែលមានពណ៌ដូចពណ៌អាវ ។

-នៅចុងកអាវទាំងសងខាង មានរូបសញ្ញាក្រសួងមហាផ្ទៃ ពណ៌មាស ដែលមានអង្កត់ផ្ចិត ២៦មីលីម៉ែត្រ ដូចមានចែងក្នុងចំណុច១ នៃមាត្រា១០ នៃអនុក្រឹត្យនេះ ។

-នៅក្រោមស្មាអាវខាងស្តាំ ចុះពីថ្នេរស្មាអាវចម្ងាយ៣៥មីលីម៉ែត្រ មានប៉ាក់សញ្ញាសម្គាល់ដូចមានចែងក្នុងចំណុច២ នៃមាត្រា១០ នៃអនុក្រឹត្យនេះ ។

-នៅក្រោមស្មាអាវខាងឆ្វេង ចុះពីថ្នេរស្មាអាវចម្ងាយ៣៥មីលីម៉ែត្រ មានប៉ាក់សញ្ញាសម្គាល់ដូចមានចែងក្នុងចំណុច៣ នៃមាត្រា១០ នៃអនុក្រឹត្យនេះ ។

-នៅពីលើស្លាកឈ្មោះ មានពាក់សញ្ញាសម្គាល់ពណ៌មាស សម្រាប់សម្គាល់តាមឋានន្តរស័ក្តិនីមួយៗ នៃប្រភេទក្របខ័ណ្ឌ **ក** ដូចមានចែងក្នុងចំណុច៤ នៃមាត្រា១០ នៃអនុក្រឹត្យនេះ ។

-នៅក្រោមគម្របហោប៉ៅអាវខាងស្តាំ មានពាក់បន្ទោកសញ្ញាសម្គាល់អង្គភាពច្រកចេញចូលតែមួយ ឬការិយាល័យច្រកចេញចូលតែមួយ ជាមួយឡេវរបស់ហោប៉ៅអាវ ដូចមានចែងក្នុងចំណុច៥ នៃមាត្រា១០ នៃអនុក្រឹត្យនេះ ។

-នៅលើហោប៉ៅអាវខាងស្តាំ មានពាក់ស្លាកឈ្មោះ ដូចមានចែងក្នុងមាត្រា១១ នៃអនុក្រឹត្យនេះ ។

-នៅលើហោប៉ៅអាវខាងឆ្វេង មានពាក់សញ្ញាសម្គាល់(បារ៉ែត)គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា ។

**ខ-អាវសម្រាប់ចូលរួមក្នុងកិច្ចប្រជុំ សិក្ខាសាលា សន្និបាត និងពិធីផ្សេងៗ ៖**

-អាវសាហារីយ៉ែនដៃខ្លី កបើក កាត់រាងអាវធំ មានប៉ូលស្មាទាំងសងខាងភ្ជាប់ដោយឡេវពណ៌ដូចពណ៌អាវ ផែកខ្នងមួយ មិនជីបស្មា មិនជីបខ្នង និងមានឡេវមុខចំនួនប្រាំរូបព្រះសង្ហារពណ៌មាស និងមានទំហំ១៩មីលីម៉ែត្រ ។ អាវនេះ មានហោប៉ៅខាងមុខចំនួនបួន នៅខាងលើពីរ និងខាងក្រោមពីរ ។ ហោប៉ៅពីរខាងលើ ដេរប៉ះ បត់ផ្នត់កណ្តាល មានគម្របរាងស្លឹកពោធិ៍ ចោះរន្ធសម្រាប់ដាក់ឡេវ ដែលមានរូបព្រះសង្ហារពណ៌មាស ទំហំ១៥មីលីម៉ែត្រ ។ ហោប៉ៅពីរខាងក្រោម ដេរបង្កប់ ដែលហោប៉ៅម្ខាងៗ មានគម្របរាងស្លឹកពោធិ៍ភ្ជាប់ដោយឡេវបញ្ចោតរូបព្រះសង្ហារពណ៌មាស ទំហំ១៥មីលីម៉ែត្រ ។

-នៅចុងកអាវទាំងសងខាង មានរូបសញ្ញាក្រសួងមហាផ្ទៃ ពណ៌មាស ដែលមានអង្កត់ផ្ចិត ២៦មីលីម៉ែត្រ ដូចមានចែងក្នុងចំណុច១ នៃមាត្រា១០ នៃអនុក្រឹត្យនេះ។
-នៅក្រោមស្មាអាវខាងស្តាំ ចុះពីថ្នេរស្មាអាវចម្ងាយ៣៥មីលីម៉ែត្រ មានប៉ាក់សញ្ញាសម្គាល់ ដូចមានចែងក្នុងចំណុច២ នៃមាត្រា១០ នៃអនុក្រឹត្យនេះ ។
-នៅក្រោមស្មាអាវខាងឆ្វេង ចុះពីថ្នេរស្មាអាវចម្ងាយ៣៥មីលីម៉ែត្រ មានប៉ាក់សញ្ញាសម្គាល់ ដូចមានចែងក្នុងចំណុច៣ នៃមាត្រា១០ នៃអនុក្រឹត្យនេះ ។
-នៅពីលើស្លាកឈ្មោះ មានពាក់សញ្ញាសម្គាល់ពណ៌មាស សម្រាប់សម្គាល់តាមឋានន្តរស័ក្តិ នីមួយៗ នៃប្រភេទក្របខ័ណ្ឌ ឝ ដូចមានចែងក្នុងចំណុច៤ នៃមាត្រា១០ នៃអនុក្រឹត្យនេះ ។
-នៅក្រោមគម្របហោប៉ៅអាវខាងស្តាំ មានពាក់បន្តោកសញ្ញាសម្គាល់អង្គភាពច្រកចេញចូលតែមួយ ឬការិយាល័យច្រកចេញចូលតែមួយ ជាមួយខ្សែរបស់ហោប៉ៅអាវ ដូចមានចែងក្នុងចំណុច៥ នៃមាត្រា១០ នៃអនុក្រឹត្យនេះ ។
-នៅលើហោប៉ៅអាវខាងស្តាំ មានពាក់ស្លាកឈ្មោះ ដូចមានចែងក្នុងមាត្រា១១ នៃអនុក្រឹត្យនេះ ។
-នៅលើហោប៉ៅអាវខាងឆ្វេង មានពាក់សញ្ញាសម្គាល់(បារ៉ែត)គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា ។

**គ- អាវយឺតពណ៌ស** ៖ អាវយឺតពណ៌ស ដៃខ្លី កម្ពុល ស្ដើង សម្រាប់ពាក់ខាងក្នុងអាវសាហារីយ៉ែន ។

**ឃ-ខោជើងវែង** ៖ ពណ៌ដូចពណ៌អាវ ដេរថ្នេរបង្កប់ ចង្កេះត ជីបភ្លីខាងមុខម្ខាងពីរ និងមានហោប៉ៅ ចំនួនបី ។ ហោប៉ៅចំហៀងពីរមានមាត់បញ្ឆិត និងហោប៉ៅខាងក្រោយមួយផ្នែកខាងស្តាំ ។ ហោប៉ៅខាងក្រោយ ដេរបង្កប់ មិនមានគម្រប មានចោះរន្ធសម្រាប់ដាក់ឡេវដែលមានពណ៌ ដូចពណ៌ខោ ។

**ង-ខ្សែក្រវ៉ាត់** ៖ ខ្សែក្រវ៉ាត់ស្បែកពណ៌ខ្មៅ ក្បាលខ្សែក្រវ៉ាត់មានរូបសញ្ញាក្រសួងមហាផ្ទៃ ពណ៌មាស នៅចំកណ្ដាល ទំហំទទឹង៣៤មីលីម៉ែត្រ និងបណ្ដោយ៦៥មីលីម៉ែត្រ ។

**ច-ស្បែកជើង** ៖ ស្បែកជើងឃ្លុប កខ្លី ស្បែកពណ៌ខ្មៅ មានកែងកម្ពស់៣០មីលីម៉ែត្រ ឬកែងរាបស្មើ និងមានស្រោមជើងពណ៌ខ្មៅពាក់កណ្ដាលស្មងជើង ។

**២-ចំពោះស្ត្រី**

អាវសឺមី និងអាវសាហារីយ៉ែន គេហ្កាលពណ៌សូកូឡាស្រាល សំពត់ហ្សីបបត់ និងខោជើងវែង ពណ៌ដូចមានរូបភាពក្នុងឧបសម្ព័ន្ធទី៣ និងឧបសម្ព័ន្ធទី៤ ។

**ក-អាវសម្រាប់បំពេញការងារប្រចាំថ្ងៃ និងបេសកកម្ម** ៖

-អាវសឺមីដៃវែង កឧប មានប៉ូលស្មាទាំងសងខាង ភ្ជាប់ដោយឡេវពណ៌ដូចពណ៌អាវ មិនជីបស្មា ប៉ុន្តែជីបខ្នងសងខាង នែកចំហៀងសងខាង តាមលក្ខណៈអាវស្ត្រី និងមានឡេវមុខចំនួន ប្រាំគ្រាប់ពណ៌ដូចពណ៌អាវ ។ នៅចុងដៃអាវមានឡេវសម្រាប់បិទពណ៌ដូចពណ៌អាវចំនួនពីរ គ្រាប់ ។ អាវនេះ មានហោប៉ៅដេរប៉ះខាងលើចំនួនពីរ ដែលដេរបត់ផ្នត់កណ្ដាល មានគម្រប រាងស្លឹកពោធិ៍ ចោះរន្ធសម្រាប់ដាក់ឡេវ មានពណ៌ដូចពណ៌អាវ ។
-នៅចុងកអាវទាំងសងខាង មានរូបសញ្ញាក្រសួងមហាផ្ទៃ ពណ៌មាស ដែលមានអង្កត់ផ្ចិត២៦ មីលីម៉ែត្រ ដូចមានចែងក្នុងចំណុច១ នៃមាត្រា១០ នៃអនុក្រឹត្យនេះ។

-នៅក្រោមស្មាអាវខាងស្តាំ ចុះពីថ្នេរស្មាអាវចម្ងាយ៣៥មីលីម៉ែត្រ មានប៉ាក់សញ្ញាសម្គាល់ដូចមានចែងក្នុងចំណុច២ នៃមាត្រា១០ នៃអនុក្រឹត្យនេះ ។

-នៅក្រោមស្មាអាវខាងឆ្វេង ចុះពីថ្នេរស្មាអាវចម្ងាយ៣៥មីលីម៉ែត្រ មានប៉ាក់សញ្ញាសម្គាល់ដូចមានចែងក្នុងចំណុច៣ នៃមាត្រា១០ នៃអនុក្រឹត្យនេះ ។

-នៅពីលើស្លាកឈ្មោះ មានពាក់សញ្ញាសម្គាល់ពណ៌មាស សម្រាប់សម្គាល់តាមឋានន្តរស័ក្តិនីមួយៗ នៃប្រភេទក្របខ័ណ្ឌ **ឥ** ដូចមានចែងក្នុងចំណុច៤ នៃមាត្រា១០ នៃអនុក្រឹត្យនេះ ។

-នៅក្រោមគម្របហោប៉ៅអាវខាងស្តាំ មានពាក់បន្ទោកសញ្ញាសម្គាល់អង្គភាពច្រកចេញចូលតែមួយ ឬការិយាល័យច្រកចេញចូលតែមួយ ជាមួយឡេវរបស់ហោប៉ៅអាវ ដូចមានចែងក្នុងចំណុច៥ នៃមាត្រា១០ នៃអនុក្រឹត្យនេះ ។

-នៅលើហោប៉ៅអាវខាងស្តាំ មានពាក់ស្លាកឈ្មោះ ដូចមានចែងក្នុងមាត្រា១១ នៃអនុក្រឹត្យនេះ ។

-នៅលើហោប៉ៅអាវខាងឆ្វេង មានពាក់សញ្ញាសម្គាល់(បារ៉ែត)គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា ។

**ខ-អាវសម្រាប់ចូលរួមក្នុងកិច្ចប្រជុំ សិក្ខាសាលា សន្និបាត និងពិធីផ្សេងៗ ៖**

-អាវសាហារីយ៉ែន កបើក កាត់រាងអាវធំ ដូចបុរសដែរ ប៉ុន្តែមានជីបរាងតាមលក្ខណៈអាវស្ត្រី ។

-នៅចុងកអាវទាំងសងខាង មានរូបសញ្ញាក្រសួងមហាផ្ទៃ ពណ៌មាស ដែលមានអង្កត់ផ្ចិត២៦មីលីម៉ែត្រ ដូចមានចែងក្នុងចំណុច១ នៃមាត្រា១០ នៃអនុក្រឹត្យនេះ ។

-នៅក្រោមស្មាអាវខាងស្តាំ ចុះពីថ្នេរស្មាអាវចម្ងាយ៣៥មីលីម៉ែត្រ មានប៉ាក់សញ្ញាសម្គាល់ដូចមានចែងក្នុងចំណុច២ នៃមាត្រា១០ នៃអនុក្រឹត្យនេះ ។

-នៅក្រោមស្មាអាវខាងឆ្វេង ចុះពីថ្នេរស្មាអាវចម្ងាយ៣៥មីលីម៉ែត្រ មានប៉ាក់សញ្ញាសម្គាល់ដូចមានចែងក្នុងចំណុច៣ នៃមាត្រា១០ នៃអនុក្រឹត្យនេះ ។

-នៅពីលើស្លាកឈ្មោះ មានពាក់សញ្ញាសម្គាល់ពណ៌មាស សម្រាប់សម្គាល់តាមឋានន្តរស័ក្តិនីមួយៗ នៃប្រភេទក្របខ័ណ្ឌ **ឥ** ដូចមានចែងក្នុងចំណុច៤ នៃមាត្រា១០ នៃអនុក្រឹត្យនេះ ។

-នៅក្រោមគម្របហោប៉ៅអាវខាងស្តាំ មានពាក់បន្ទោកសញ្ញាសម្គាល់អង្គភាពច្រកចេញចូលតែមួយ ឬការិយាល័យច្រកចេញចូលតែមួយ ជាមួយឡេវរបស់ហោប៉ៅអាវ ដូចមានចែងក្នុងចំណុច៥ នៃមាត្រា១០ នៃអនុក្រឹត្យនេះ ។

-នៅលើហោប៉ៅអាវខាងស្តាំ មានពាក់ស្លាកឈ្មោះ ដូចមានចែងក្នុងមាត្រា១១ នៃអនុក្រឹត្យនេះ ។

-នៅលើហោប៉ៅអាវខាងឆ្វេង មានពាក់សញ្ញាសម្គាល់(បារ៉ែត)គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា ។

**គ-សំពត់៖** សំពត់ហ្សីបបត់ពណ៌ដូចពណ៌អាវ មានសម្រុងក្រោមក្បាលជង្គង់ សម្រាប់ប្រើជាមួយអាវសាហារីយ៉ែន ឬអាវបំពេញការងារប្រចាំថ្ងៃ ។

**ឃ-ខោជើងវែង** ៖ ខោជើងវែង ដូចបុរសដែរ ប៉ុន្តែគ្មានហោប៉ៅក្រោយ សម្រាប់ប្រើជាមួយអាវបំពេញបេសកកម្ម ។

**ង-ខ្សែក្រវ៉ាត់** ៖ ខ្សែក្រវ៉ាត់ស្បែកពណ៌ខ្មៅ ក្បាលខ្សែក្រវ៉ាត់មានរូបសញ្ញាក្រសួងមហាផ្ទៃ នៅចំកណ្តាលពណ៌មាស ទំហំទទឹង៣៤មីលីម៉ែត្រ និងបណ្តោយ៦៥មីលីម៉ែត្រ ។

ច-ស្បែកជើង ៖ ស្បែកជើងកែងចោត កខ្លី មានកែងកម្ពស់៥០មីលីម៉ែត្រ ឬកែងរាបស្មើ ស្បែកពណ៌ខ្មៅ និងមានស្រោមជើងកខ្លីពណ៌ខ្មៅ ។

## ផ្នែកទី២

## ឯកសណ្ឋានការងារសម្រាប់មន្ត្រីក្របខ័ណ្ឌប្រភេទ ខ

**មាត្រា ៥ .-**

ឯកសណ្ឋានការងារសម្រាប់មន្ត្រីក្របខ័ណ្ឌប្រភេទ **ខ** ដែលបម្រើការងារនៅទីស្តីការក្រសួងមហាផ្ទៃ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានកំណត់ដូចខាងក្រោម ៖

**១-ចំពោះបុរស**

អាវសឺមី និងអាវសាហារីយ៉ែន តេហ្គាលពណ៌សូកូឡាស្រាល និងខោជើងវែង ពណ៌ដូចមានរូបភាពក្នុងឧបសម្ព័ន្ធទី៥ និងឧបសម្ព័ន្ធទី៦ ។

**ក-អាវសម្រាប់បំពេញការងារប្រចាំថ្ងៃ និងបេសកកម្ម ៖**

-អាវសឺមីដៃវែង កឧប មានប៉ូលស្មាទាំងសងខាង ភ្ជាប់ដោយឡេវពណ៌ដូចពណ៌អាវ មិនជីបស្មា មិនជីបខ្នង ផែកចំហៀងសងខាង មានឡេវមុខចំនួនប្រាំគ្រាប់ពណ៌ដូចពណ៌អាវ ។ នៅចុងដៃអាវមានឡេវសម្រាប់បិទពណ៌ ដូចពណ៌អាវចំនួនពីរគ្រាប់ ។ អាវនេះ មានហោប៉ៅដេរប៉ះខាងលើចំនួនពីរដែលដេរបត់ផ្នត់កណ្តាល មានគម្របរាងស្លឹកពោធិ៍ ចោះរន្ធសម្រាប់ដាក់ឡេវ ដែលមានពណ៌ដូចពណ៌អាវ ។

-នៅចុងកអាវទាំងសងខាង មានរូបសញ្ញាក្រសួងមហាផ្ទៃ ពណ៌ប្រាក់ ដែលមានអង្កត់ផ្ចិត ២៦ មីលីម៉ែត្រ ដូចមានចែងក្នុងចំណុច១ នៃមាត្រា១០ នៃអនុក្រឹត្យនេះ ។

-នៅក្រោមស្មាអាវខាងស្តាំ ចុះពីថ្នេរស្មាអាវចម្ងាយ៣៥មីលីម៉ែត្រ មានប៉ាក់សញ្ញាសម្គាល់ ដូចមានចែងក្នុងចំណុច២ នៃមាត្រា១០ នៃអនុក្រឹត្យនេះ ។

-នៅក្រោមស្មាអាវខាងឆ្វេង ចុះពីថ្នេរស្មាអាវចម្ងាយ៣៥មីលីម៉ែត្រ មានប៉ាក់សញ្ញាសម្គាល់ ដូចមានចែងក្នុងចំណុច៣ នៃមាត្រា១០ នៃអនុក្រឹត្យនេះ ។

-នៅពីលើស្លាកឈ្មោះ មានពាក់សញ្ញាសម្គាល់ពណ៌ប្រាក់ សម្រាប់សម្គាល់តាមឋានន្តរស័ក្តិនីមួយៗ នៃប្រភេទក្របខ័ណ្ឌ **ខ** ដូចមានចែងក្នុងចំណុច៤ នៃមាត្រា១០ នៃអនុក្រឹត្យនេះ ។

-នៅក្រោមគម្របហោប៉ៅអាវខាងស្តាំ មានពាក់បន្តោកសញ្ញាសម្គាល់អង្គភាពច្រកចេញចូលតែមួយ ឬការិយាល័យច្រកចេញចូលតែមួយ ជាមួយឡេវរបស់ហោប៉ៅអាវ ដូចមានចែងក្នុងចំណុច៥ នៃមាត្រា១០ នៃអនុក្រឹត្យនេះ ។

-នៅលើហោប៉ៅអាវខាងស្តាំ មានពាក់ស្លាកឈ្មោះ ដូចមានចែងក្នុងមាត្រា១១ នៃអនុក្រឹត្យនេះ ។

-នៅលើហោប៉ៅអាវខាងឆ្វេង មានពាក់សញ្ញាសម្គាល់ ( បារ៉ែត ) គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា ។

**ខ-អាវសម្រាប់ចូលរួមក្នុងកិច្ចប្រជុំ សិក្ខាសាលា សន្និបាត និងពិធីផ្សេងៗ ៖**

-អាវសាហារីយ៉ែនដៃខ្លី កបើក កាត់រាងអាវធំ មានប៉ូលស្មាទាំងសងខាងភ្ជាប់ដោយឡេវពណ៌ដូចពណ៌អាវ ផែកខ្នងមួយ មិនជីបស្មា មិនជីបខ្នង និងមានឡេវមុខចំនួនប្រាំរូបព្រះសង្ហារពណ៌

ប្រាក់ និងមានទំហំ១៩មីលីម៉ែត្រ ។ អាវនេះ មានហោប៉ៅខាងមុខចំនួនបួន នៅខាងលើពីរ និងខាងក្រោមពីរ ។ ហោប៉ៅពីរខាងលើ ដេរប៉ះ បត់ផ្នត់កណ្តាល មានគម្របរាងស្លឹកពោធិ៍ ចោះរន្ធសម្រាប់ដាក់ឡេវ ដែលមានរូបព្រះសង្ហារពណ៌ប្រាក់ ទំហំ១៥មីលីម៉ែត្រ ។ ហោប៉ៅពីរខាងក្រោមដេរបង្កប់ ដែលហោប៉ៅម្ខាងៗ មានគម្របរាងស្លឹកពោធិ៍ភ្ជាប់ដោយឡេវបញ្ចោតរូបព្រះសង្ហារពណ៌ប្រាក់ ទំហំ១៥ មីលីម៉ែត្រ ។

-នៅចុងកអាវទាំងសងខាង មានរូបសញ្ញាក្រសួងមហាផ្ទៃ ពណ៌ប្រាក់ ដែលមានអង្កត់ផ្ចិត២៦មីលីម៉ែត្រ ដូចមានចែងក្នុងចំណុច១ នៃមាត្រា១០ នៃអនុក្រឹត្យនេះ ។

-នៅក្រោមស្មាអាវខាងស្តាំ ចុះពីថ្នេរស្មាអាវចម្ងាយ៣៥មីលីម៉ែត្រ មានប៉ាក់សញ្ញាសម្គាល់ដូចមានចែងក្នុងចំណុច២ នៃមាត្រា១០ នៃអនុក្រឹត្យនេះ ។

-នៅក្រោមស្មាអាវខាងឆ្វេង ចុះពីថ្នេរស្មាអាវចម្ងាយ៣៥មីលីម៉ែត្រ មានប៉ាក់សញ្ញាសម្គាល់ដូចមានចែងក្នុងចំណុច៣ នៃមាត្រា១០ នៃអនុក្រឹត្យនេះ ។

-នៅពីលើស្លាកឈ្មោះ មានពាក់សញ្ញាសម្គាល់ពណ៌ប្រាក់ សម្រាប់សម្គាល់តាមឋានន្តរស័ក្តិនីមួយៗ នៃប្រភេទក្របខ័ណ្ឌ **ខ** ដូចមានចែងក្នុងចំណុច៤ នៃមាត្រា១០ នៃអនុក្រឹត្យនេះ ។

-នៅក្រោមគម្របហោប៉ៅអាវខាងស្តាំ មានពាក់បន្តោកសញ្ញាសម្គាល់អង្គភាពច្រកចេញចូលតែមួយ ឬការិយាល័យច្រកចេញចូលតែមួយ ជាមួយឡេវរបស់ហោប៉ៅអាវ ដូចមានចែងក្នុងចំណុច៥ នៃមាត្រា១០ នៃអនុក្រឹត្យនេះ ។

-នៅលើហោប៉ៅអាវខាងស្តាំ មានពាក់ស្លាកឈ្មោះ ដូចមានចែងក្នុងមាត្រា១១ នៃអនុក្រឹត្យនេះ ។

-នៅលើហោប៉ៅអាវខាងឆ្វេង មានពាក់សញ្ញាសម្គាល់(បារ៉ែត)គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា ។

**គ-អាវយឺតពណ៌ស** ៖ អាវយឺតពណ៌ស ដៃខ្លី កមូល ស្តើង សម្រាប់ពាក់ខាងក្នុងអាវសាហារីយ៉ែន ។

**ឃ-ខោជើងវែង** ៖ ពណ៌ដូចពណ៌អាវ ដេរថ្នេរបង្កប់ ចង្កេះត ជីបភ្លីខាងមុខម្ខាងពីរ និងមានហោប៉ៅចំនួនបី ។ ហោប៉ៅចំហៀងពីរមានមាត់បញ្ឆិត និងហោប៉ៅខាងក្រោយមួយផ្នែកខាងស្តាំ ។ ហោប៉ៅខាងក្រោយ ដេរបង្កប់ មិនមានគម្រប មានចោះរន្ធសម្រាប់ដាក់ឡេវដែលមានពណ៌ដូចពណ៌ខោ ។

**ង-ខ្សែក្រវ៉ាត់** ៖ ខ្សែក្រវ៉ាត់ស្បែកពណ៌ខ្មៅ ក្បាលខ្សែក្រវ៉ាត់មានរូបសញ្ញាក្រសួងមហាផ្ទៃ ពណ៌ប្រាក់នៅចំកណ្តាល ទំហំទទឹង៣៤មីលីម៉ែត្រ និងបណ្តោយ៦៥មីលីម៉ែត្រ ។

**ច-ស្បែកជើង** ៖ ស្បែកជើងឃ្លុប កខ្លី ស្បែកពណ៌ខ្មៅ មានកែងកម្ពស់៣០មីលីម៉ែត្រ ឬកែងរាបស្មើ និងមានស្រោមជើងពណ៌ខ្មៅពាក់កណ្តាលស្មងជើង ។

**២-ចំពោះស្ត្រី**

អាវសឺមី និងអាវសាហារីយ៉ែន តេហ្គាលពណ៌សូកូឡាស្រាល សំពត់ហ្សីបបត់ និងខោជើងវែងពណ៌ដូចមានរូបភាពក្នុងឧបសម្ព័ន្ធទី៧ និងឧបសម្ព័ន្ធទី៨ ។

**ក-អាវសម្រាប់បំពេញការងារប្រចាំថ្ងៃ និងបេសកកម្ម** ៖

-អាវសឺមីដៃវែង កឌុប មានប៉ូលស្មាទាំងសងខាង ភ្ជាប់ដោយឡេវពណ៌ដូចពណ៌អាវ មិនជីបស្មា ប៉ុន្តែជីបខ្នងសងខាង នែកចំហៀងសងខាង តាមលក្ខណៈអាវស្ត្រី និងមានឡេវមុខចំនួន

ប្រាំគ្រាប់ពណ៌ដូចពណ៌អាវ ។ នៅចុងដៃអាវមានឡេវសម្រាប់បិទពណ៌ដូចពណ៌អាវ ចំនួនពីរគ្រាប់ ។ អាវនេះ មានហោប៉ៅដេរប៉ះខាងលើចំនួនពីរដែលដេរបត់ផ្នត់កណ្ដាល មានគម្របរាងស្លឹកពោធិ៍ ចោះរន្ធសម្រាប់ដាក់ឡេវដែលមានពណ៌ដូចពណ៌អាវ ។

-នៅចុង កអាវទាំងសងខាង មានរូបសញ្ញាក្រសួងមហាផ្ទៃ ពណ៌ប្រាក់ ដែលមានអង្កត់ផ្ចិត២៦មីលីម៉ែត្រ ដូចមានចែងក្នុងចំណុច១ នៃមាត្រា១០ នៃអនុក្រឹត្យនេះ ។

-នៅក្រោមស្មាអាវខាងស្ដាំ ចុះពីថ្នេរស្មាអាវចម្ងាយ៣៥មីលីម៉ែត្រ មានប៉ាក់សញ្ញាសម្គាល់ដូចមានចែងក្នុងចំណុច២ នៃមាត្រា១០ នៃអនុក្រឹត្យនេះ ។

-នៅក្រោមស្មាអាវខាងឆ្វេង ចុះពីថ្នេរស្មាអាវចម្ងាយ៣៥មីលីម៉ែត្រ មានប៉ាក់សញ្ញាសម្គាល់ដូចមានចែងក្នុងចំណុច៣ នៃមាត្រា១០ នៃអនុក្រឹត្យនេះ ។

-នៅពីលើស្លាកឈ្មោះ មានពាក់សញ្ញាសម្គាល់ពណ៌ប្រាក់ សម្រាប់សម្គាល់តាមឋានន្តរស័ក្តិនីមួយៗ នៃប្រភេទក្របខ័ណ្ឌ **ខ** ដូចមានចែងក្នុងចំណុច៤ នៃមាត្រា១០ នៃអនុក្រឹត្យនេះ ។

-នៅក្រោមគម្របហោប៉ៅអាវខាងស្ដាំ មានពាក់បន្តោកសញ្ញាសម្គាល់អង្គភាពច្រកចេញចូលតែមួយ ឬការិយាល័យច្រកចេញចូលតែមួយ ជាមួយឡេវរបស់ហោប៉ៅអាវ ដូចមានចែងក្នុងចំណុច៥ នៃមាត្រា១០ នៃអនុក្រឹត្យនេះ ។

-នៅលើហោប៉ៅអាវខាងស្ដាំ មានពាក់ស្លាកឈ្មោះ ដូចមានចែងក្នុងមាត្រា១១ នៃអនុក្រឹត្យនេះ ។

-នៅលើហោប៉ៅអាវខាងឆ្វេង មានពាក់សញ្ញាសម្គាល់(បារ៉ែត)គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា ។

**ខ-អាវសម្រាប់ចូលរួមក្នុងកិច្ចប្រជុំ សិក្ខាសាលា សន្និបាត និងពិធីផ្សេងៗ ៖**

-អាវសាហារីយ៉េន កបើក កាត់រាងអាវធំ ដូចបុរសដែរ ប៉ុន្តែមានជីបរាងតាមលក្ខណៈអាវស្ត្រី ។

-នៅចុងកអាវទាំងសងខាង មានរូបសញ្ញាក្រសួងមហាផ្ទៃ ពណ៌ប្រាក់ ដែលមានអង្កត់ផ្ចិត២៦មីលីម៉ែត្រ ដូចមានចែងក្នុងចំណុច១ នៃមាត្រា១០ នៃអនុក្រឹត្យនេះ ។

-នៅក្រោមស្មាអាវខាងស្ដាំ ចុះពីថ្នេរស្មាអាវចម្ងាយ៣៥មីលីម៉ែត្រ មានប៉ាក់សញ្ញាសម្គាល់ដូចមានចែងក្នុងចំណុច២ នៃមាត្រា១០ នៃអនុក្រឹត្យនេះ ។

-នៅក្រោមស្មាអាវខាងឆ្វេង ចុះពីថ្នេរស្មាអាវចម្ងាយ៣៥មីលីម៉ែត្រ មានប៉ាក់សញ្ញាសម្គាល់ដូចមានចែងក្នុងចំណុច៣ នៃមាត្រា១០ នៃអនុក្រឹត្យនេះ ។

-នៅពីលើស្លាកឈ្មោះ មានពាក់សញ្ញាសម្គាល់ពណ៌ប្រាក់ សម្រាប់សម្គាល់តាមឋានន្តរស័ក្តិនីមួយៗ នៃប្រភេទក្របខ័ណ្ឌ **ខ** ដូចមានចែងក្នុងចំណុច៤ នៃមាត្រា១០ នៃអនុក្រឹត្យនេះ ។

-នៅក្រោមគម្របហោប៉ៅអាវខាងស្ដាំ មានពាក់បន្តោកសញ្ញាសម្គាល់អង្គភាពច្រកចេញចូលតែមួយ ឬការិយាល័យច្រកចេញចូលតែមួយ ជាមួយឡេវរបស់ហោប៉ៅអាវ ដូចមានចែងក្នុងចំណុច៥ នៃមាត្រា១០ នៃអនុក្រឹត្យនេះ ។

-នៅលើហោប៉ៅអាវខាងស្ដាំ មានពាក់ស្លាកឈ្មោះ ដូចមានចែងក្នុងមាត្រា១១ នៃអនុក្រឹត្យនេះ ។

-នៅលើហោប៉ៅអាវខាងឆ្វេង មានពាក់សញ្ញាសម្គាល់(បារ៉ែត)គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា ។

គ-សំពត់ ៖ សំពត់ហ្សីបបត់ ពណ៌ដូចអាវ មានសម្រុងក្រោមក្បាលជង្គង់ សម្រាប់ប្រើជាមួយអាវសាហារីយ៉ែន ឬអាវបំពេញការងារប្រចាំថ្ងៃ ។

ឃ-ខោជើងវែង ៖ ខោជើងវែង ដូចបុរសដែរ ប៉ុន្តែគ្មានហោប៉ៅក្រោយ សម្រាប់ប្រើជាមួយអាវបំពេញបេសកកម្ម ។

ង-ខ្សែក្រវ៉ាត់ ៖ ខ្សែក្រវ៉ាត់ស្បែកពណ៌ខ្មៅ ក្បាលខ្សែក្រវ៉ាត់មានរូបសញ្ញាក្រសួងមហាផ្ទៃ នៅចំកណ្តាលពណ៌ប្រាក់ ទំហំទទឹង៣៤មីលីម៉ែត្រ និងបណ្តោយ៦៥មីលីម៉ែត្រ ។

ច-ស្បែកជើង ៖ ស្បែកជើងកែងចោត កខ្លី មានកែងកម្ពស់៥០មីលីម៉ែត្រ ឬកែងរាបស្មើ ស្បែកពណ៌ខ្មៅ និងមានស្រោមជើងកខ្លីពណ៌ខ្មៅ ។

## ផ្នែកទី៣

## ឯកសណ្ឋានការងារសម្រាប់មន្ត្រីក្របខ័ណ្ឌប្រភេទ គ

**មាត្រា ៦ .–**

ឯកសណ្ឋានការងារសម្រាប់មន្ត្រីក្របខ័ណ្ឌប្រភេទ **គ** ដែលបម្រើការងារនៅទីស្តីការក្រសួងមហាផ្ទៃ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានកំណត់ដូចខាងក្រោម ៖

**១-ចំពោះបុរស**

អាវសឺមី និងអាវសាហារីយ៉ែន តេហ្គាលពណ៌សូកូឡាស្រាល និងខោជើងវែង ពណ៌ដូចមានរូបភាពក្នុងឧបសម្ព័ន្ធទី៩ និងឧបសម្ព័ន្ធទី១០ ។

**ក-អាវសម្រាប់បំពេញការងារប្រចាំថ្ងៃ និងបេសកកម្ម ៖**

-អាវសឺមីដៃវែង កឧប មានប៉ូលស្មាទាំងសងខាង ភ្ជាប់ដោយឡេវពណ៌ដូចពណ៌អាវ មិនជីបស្មា មិនជីបខ្នង ឆែកចំហៀងសងខាង មានឡេវមុខចំនួនប្រាំគ្រាប់ពណ៌ដូចពណ៌អាវ ។ នៅចុងដៃអាវមានឡេវសម្រាប់បិទពណ៌ ដូចពណ៌អាវចំនួនពីរគ្រាប់ ។ អាវនេះ មានហោប៉ៅដេរប៉ះខាងលើចំនួនពីរដែលដេរបត់ផ្នត់កណ្តាល មានគម្របរាងស្លឹកពោធិ៍ ចោះរន្ធសម្រាប់ដាក់ឡេវ ដែលមានពណ៌ដូចពណ៌អាវ ។

-នៅចុងកអាវទាំងសងខាង មានរូបសញ្ញាក្រសួងមហាផ្ទៃ ពណ៌សំរឹទ្ធ ដែលមានអង្កត់ផ្ចិត២៦មីលីម៉ែត្រ ដូចមានចែងក្នុងចំណុច១ នៃមាត្រា១០ នៃអនុក្រឹត្យនេះ ។

-នៅក្រោមស្មាអាវខាងស្តាំ ចុះពីថ្នេរស្មាអាវចម្ងាយ៣៥មីលីម៉ែត្រ មានប៉ាក់សញ្ញាសម្គាល់ ដូចមានចែងក្នុងចំណុច២ នៃមាត្រា១០ នៃអនុក្រឹត្យនេះ ។

-នៅក្រោមស្មាអាវខាងឆ្វេង ចុះពីថ្នេរស្មាអាវចម្ងាយ៣៥មីលីម៉ែត្រ មានប៉ាក់សញ្ញាសម្គាល់ ដូចមានចែងក្នុងចំណុច៣ នៃមាត្រា១០ នៃអនុក្រឹត្យនេះ ។

-នៅពីលើស្លាកឈ្មោះ មានពាក់សញ្ញាសម្គាល់ពណ៌សំរឹទ្ធ សម្រាប់សម្គាល់តាមឋានន្តរស័ក្តិនីមួយៗ នៃប្រភេទក្របខ័ណ្ឌ **គ** ដូចមានចែងក្នុងចំណុច៤ នៃមាត្រា១០ នៃអនុក្រឹត្យនេះ ។

-នៅក្រោមគម្របហោប៉ៅអាវខាងស្តាំ មានពាក់បន្ទោកសញ្ញាសម្គាល់អង្គភាពច្រកចេញចូលតែមួយ ឬការិយាល័យច្រកចេញចូលតែមួយ ជាមួយឡេវរបស់ហោប៉ៅអាវ ដូចមានចែងក្នុងចំណុច៥ នៃមាត្រា១០ នៃអនុក្រឹត្យនេះ ។

-នៅលើហោប៉ៅអាវខាងស្តាំ មានពាក់ស្លាកឈ្មោះ ដូចមានចែងក្នុងមាត្រា១១ នៃអនុក្រឹត្យនេះ ។

-នៅលើហោប៉ៅអាវខាងឆ្វេង មានពាក់សញ្ញាសម្គាល់(បារ៉ែត)គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា ។

**ខ-អាវសម្រាប់ចូលរួមក្នុងកិច្ចប្រជុំ សិក្ខាសាលា សន្និបាត និងពិធីផ្សេងៗ ៖**

-អាវសាហារីយ៉ែនដៃខ្លី កបើក កាត់រាងអាវធំ មានប៊ូលស្មាទាំងសងខាងភ្ជាប់ដោយឡេវពណ៌ដូចពណ៌អាវ ផែកខ្នងមួយ មិនជីបស្មា មិនជីបខ្នង និងមានឡេវមុខចំនួនប្រាំរូបព្រះសង្ហារពណ៌សំរឹទ្ធ និងមានទំហំ១៩មីលីម៉ែត្រ ។ អាវនេះ មានហោប៉ៅខាងមុខចំនួនបួន នៅខាងលើពីរ និងខាងក្រោមពីរ ។ ហោប៉ៅពីរខាងលើ ដេរប៉ះ បត់ផ្នត់កណ្តាល មានគម្របរាងស្លឹកពោធិ៍ ចោះរន្ធសម្រាប់ដាក់ឡេវ ដែលមានរូបព្រះសង្ហារពណ៌សំរឹទ្ធ ទំហំ១៥ មីលីម៉ែត្រ ។ ហោប៉ៅពីរខាងក្រោមដេរបង្កប់ ដែលហោប៉ៅម្ខាងៗ មានគម្របរាងស្លឹកពោធិ៍ភ្ជាប់ដោយឡេវបញ្ចោតរូបព្រះសង្ហារពណ៌សំរឹទ្ធ ទំហំ១៥ មីលីម៉ែត្រ ។

-នៅចុងកអាវទាំងសងខាង មានរូបសញ្ញាក្រសួងមហាផ្ទៃ ពណ៌សំរឹទ្ធ ដែលមានអង្កត់ផ្ចិត២៦ មីលីម៉ែត្រ ដូចមានចែងក្នុងចំណុច១ នៃមាត្រា១០ នៃអនុក្រឹត្យនេះ ។

-នៅក្រោមស្មាអាវខាងស្តាំ ចុះពីថ្នេរស្មាអាវចម្ងាយ៣៥មីលីម៉ែត្រ មានប៉ាក់សញ្ញាសម្គាល់ដូចមានចែងក្នុងចំណុច២ នៃមាត្រា១០ នៃអនុក្រឹត្យនេះ ។

-នៅក្រោមស្មាអាវខាងឆ្វេង ចុះពីថ្នេរស្មាអាវចម្ងាយ៣៥មីលីម៉ែត្រ មានប៉ាក់សញ្ញាសម្គាល់ដូចមានចែងក្នុងចំណុច៣ នៃមាត្រា១០ នៃអនុក្រឹត្យនេះ ។

-នៅពីលើស្លាកឈ្មោះ មានពាក់សញ្ញាសម្គាល់ពណ៌សំរឹទ្ធ សម្រាប់សម្គាល់តាមឋានន្តរស័ក្តិនីមួយៗ នៃប្រភេទក្របខ័ណ្ឌ **គ** ដូចមានចែងក្នុងចំណុច៤ នៃមាត្រា១០ នៃអនុក្រឹត្យនេះ ។

-នៅក្រោមគម្របហោប៉ៅអាវខាងស្តាំ មានពាក់បន្តោកសញ្ញាសម្គាល់អង្គភាពច្រកចេញចូលតែមួយ ឬការិយាល័យច្រកចេញចូលតែមួយ ជាមួយឡេវរបស់ហោប៉ៅអាវ ដូចមានចែងក្នុងចំណុច៥ នៃមាត្រា១០ នៃអនុក្រឹត្យនេះ ។

-នៅលើហោប៉ៅអាវខាងស្តាំ មានពាក់ស្លាកឈ្មោះ ដូចមានចែងក្នុងមាត្រា១១ នៃអនុក្រឹត្យនេះ ។

-នៅលើហោប៉ៅអាវខាងឆ្វេង មានពាក់សញ្ញាសម្គាល់(បារ៉ែត)គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា ។

**គ-អាវយឺតពណ៌ស** ៖ អាវយឺតពណ៌ស ដៃខ្លី កមូល ស្តើង សម្រាប់ពាក់ខាងក្នុងអាវសាហារីយ៉ែន ។

**ឃ-ខោជើងវែង** ៖ ពណ៌ដូចពណ៌អាវ ដេរថ្នេរបង្កប់ ចង្កេះត ជីបក្លីខាងមុខម្ខាងពីរ និងមានហោប៉ៅចំនួនបី ។ ហោប៉ៅចំហៀងពីរមានមាត់បញ្ឆិត និងហោប៉ៅខាងក្រោយមួយផ្នែកខាងស្តាំ ។ ហោប៉ៅខាងក្រោយ ដេរបង្កប់ មិនមានគម្រប មានចោះរន្ធសម្រាប់ដាក់ឡេវដែលមានពណ៌ដូចពណ៌ខោ ។

**ង-ខ្សែក្រវ៉ាត់** ៖ ខ្សែក្រវ៉ាត់ស្បែកពណ៌ខ្មៅ ក្បាលខ្សែក្រវ៉ាត់មានរូបសញ្ញាក្រសួងមហាផ្ទៃពណ៌សំរឹទ្ធនៅចំកណ្តាល ទំហំទទឹង៣៨មីលីម៉ែត្រ និងបណ្តោយ៦៥មីលីម៉ែត្រ ។

**ច-ស្បែកជើង** ៖ ស្បែកជើងឃ្លុប កខ្លី ស្បែកពណ៌ខ្មៅ មានកែងកម្ពស់៣០មីលីម៉ែត្រ ឬកែងរាបស្មើ និងមានស្រោមជើងពណ៌ខ្មៅពាក់កណ្តាលស្មងជើង ។

**២-ចំពោះស្ត្រី**

អាវសឺមី និងអាវសាហារីយ៉ែន តេហ្គាលពណ៌សូកូឡាស្រាល សំពត់ហ្សីបបត់ និងខោជើងវែង ពណ៌ដូចមានរូបភាពក្នុងឧបសម្ព័ន្ធទី១១ និងឧបសម្ព័ន្ធទី១២ ។

**ក-អាវសម្រាប់បំពេញការងារប្រចាំថ្ងៃ និងបេសកកម្ម ៖**

-អាវសឺមីដៃវែង កឧប មានប៉ូលស្មាទាំងសងខាង ភ្ជាប់ដោយឡេវពណ៌ដូចពណ៌អាវ មិនជីបស្មា ប៉ុន្តែជីបខ្នងសងខាង ផែកចំហៀងសងខាង តាមលក្ខណៈអាវស្ត្រី និងមានឡេវមុខចំនួន ប្រាំគ្រាប់ពណ៌ដូចពណ៌អាវ ។ នៅចុងដៃអាវមានឡេវសម្រាប់បិទពណ៌ដូចពណ៌អាវ ចំនួនពីរ គ្រាប់ ។ អាវនេះ មានហោប៉ៅដេរប៉ះខាងលើចំនួនពីរដែលដេរបត់ផ្នត់កណ្តាល មានគម្របរាង ស្លឹកពោធិ៍ ចោះរន្ធសម្រាប់ដាក់ឡេវដែលមានពណ៌ដូចពណ៌អាវ ។

-នៅចុងកអាវទាំងសងខាង មានរូបសញ្ញាក្រសួងមហាផ្ទៃ ពណ៌សំរិទ្ធ ដែលមានអង្កត់ផ្ចិត២៦ មីលីម៉ែត្រ ដូចមានចែងក្នុងចំណុច១ នៃមាត្រា១០ នៃអនុក្រឹត្យនេះ ។

-នៅក្រោមស្មាអាវខាងស្តាំ ចុះពីថ្នេរស្មាអាវចម្ងាយ៣៥មីលីម៉ែត្រ មានប៉ាក់សញ្ញាសម្គាល់ ដូចមានចែងក្នុងចំណុច២ នៃមាត្រា១០ នៃអនុក្រឹត្យនេះ ។

-នៅក្រោមស្មាអាវខាងឆ្វេង ចុះពីថ្នេរស្មាអាវចម្ងាយ៣៥មីលីម៉ែត្រ មានប៉ាក់សញ្ញាសម្គាល់ ដូចមានចែងក្នុងចំណុច៣ នៃមាត្រា១០ នៃអនុក្រឹត្យនេះ ។

-នៅពីលើស្លាកឈ្មោះ មានពាក់សញ្ញាសម្គាល់ពណ៌សំរិទ្ធ សម្រាប់សម្គាល់តាមឋានន្តរស័ក្តិ នីមួយៗ នៃប្រភេទក្របខ័ណ្ឌ **ឝ** ដូចមានចែងក្នុងចំណុច៤ នៃមាត្រា១០ នៃអនុក្រឹត្យនេះ ។

-នៅក្រោមគម្របហោប៉ៅអាវខាងស្តាំ មានពាក់បន្តោកសញ្ញាសម្គាល់អង្គភាពច្រកចេញចូលតែមួយ ឬការិយាល័យច្រកចេញចូលតែមួយ ជាមួយឡេវរបស់ហោប៉ៅអាវ ដូចមានចែងក្នុងចំណុច៥ នៃមាត្រា១០ នៃអនុក្រឹត្យនេះ ។

-នៅលើហោប៉ៅអាវខាងស្តាំ មានពាក់ស្លាកឈ្មោះ ដូចមានចែងក្នុងមាត្រា១១ នៃអនុក្រឹត្យនេះ ។

-នៅលើហោប៉ៅអាវខាងឆ្វេង មានពាក់សញ្ញាសម្គាល់(បារ៉ែត)គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា ។

**ខ-អាវសម្រាប់ចូលរួមក្នុងកិច្ចប្រជុំ សិក្ខាសាលា សន្និបាត និងពិធីផ្សេងៗ ៖**

-អាវសាហារីយ៉ែន កបើក កាត់រាងអាវធំ ដូចបុរសដែរ ប៉ុន្តែមានជីបរាងតាមលក្ខណៈអាវស្ត្រី ។

-នៅចុងកអាវទាំងសងខាង មានរូបសញ្ញាក្រសួងមហាផ្ទៃ ពណ៌សំរិទ្ធ ដែលមានអង្កត់ផ្ចិត២៦ មីលីម៉ែត្រ ដូចមានចែងក្នុងចំណុច១ នៃមាត្រា១០ នៃអនុក្រឹត្យនេះ ។

-នៅក្រោមស្មាអាវខាងស្តាំ ចុះពីថ្នេរស្មាអាវចម្ងាយ៣៥មីលីម៉ែត្រ មានប៉ាក់សញ្ញាសម្គាល់ ដូចមានចែងក្នុងចំណុច២ នៃមាត្រា១០ នៃអនុក្រឹត្យនេះ ។

-នៅក្រោមស្មាអាវខាងឆ្វេង ចុះពីថ្នេរស្មាអាវចម្ងាយ៣៥មីលីម៉ែត្រ មានប៉ាក់សញ្ញាសម្គាល់ ដូចមានចែងក្នុងចំណុច៣ នៃមាត្រា១០ នៃអនុក្រឹត្យនេះ ។

-នៅពីលើស្លាកឈ្មោះ មានពាក់សញ្ញាសម្គាល់ពណ៌សំរិទ្ធ សម្រាប់សម្គាល់តាមឋានន្តរស័ក្តិ នីមួយៗ នៃប្រភេទក្របខ័ណ្ឌ **ឝ** ដូចមានចែងក្នុងចំណុច៤ នៃមាត្រា១០ នៃអនុក្រឹត្យនេះ ។

-នៅក្រោមគម្របហោប៉ៅអាវខាងស្តាំ មានពាក់បន្តោកសញ្ញាសម្គាល់អង្គភាពច្រកចេញចូលតែមួយ ឬការិយាល័យច្រកចេញចូលតែមួយ ជាមួយឡេវរបស់ហោប៉ៅអាវ ដូចមានចែងក្នុងចំណុច៥ នៃមាត្រា១០ នៃអនុក្រឹត្យនេះ ។

-នៅលើហោប៉ៅអាវខាងស្តាំ មានពាក់ស្លាកឈ្មោះ ដូចមានចែងក្នុងមាត្រា១១ នៃអនុក្រឹត្យនេះ ។
-នៅលើហោប៉ៅអាវខាងឆ្វេង មានពាក់សញ្ញាសម្គាល់(បារ៉ែត)គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា ។

**គ-សំពត់** ៖ សំពត់ហ្សិបបត់ ពណ៌ដូចអាវ មានសម្រុងក្រោមក្បាលជង្គង់ សម្រាប់ប្រើជាមួយអាវសាហារីយ៉ែន ឬអាវបំពេញការងារប្រចាំថ្ងៃ ។

**ឃ-ខោជើងវែង** ៖ ខោជើងវែង ដូចបុរសដែរ ប៉ុន្តែគ្មានហោប៉ៅក្រោយ សម្រាប់ប្រើជាមួយអាវបំពេញបេសកកម្ម ។

**ង-ខ្សែក្រវ៉ាត់** ៖ ខ្សែក្រវ៉ាត់ស្បែកពណ៌ខ្មៅ ក្បាលខ្សែក្រវ៉ាត់មានរូបសញ្ញាក្រសួងមហាផ្ទៃ នៅចំកណ្តាលពណ៌សំរឹទ្ធ ទំហំទទឹង៣៨មីលីម៉ែត្រ និងបណ្តោយ៦៥មីលីម៉ែត្រ ។

**ច-ស្បែកជើង** ៖ ស្បែកជើងកែងចោត កខ្លី មានកែងកម្ពស់៥០មីលីម៉ែត្រ ឬកែងរាបស្មើ ស្បែកពណ៌ខ្មៅ និងមានស្រោមជើងកខ្លីពណ៌ខ្មៅ ។

## ជំពូកទី៣
## មួក សញ្ញាស័ក្តិស្មា សញ្ញាសម្គាល់ និងស្លាកឈ្មោះ

**មាត្រា ៧ .―**

មួក សញ្ញាស័ក្តិស្មា សញ្ញាសម្គាល់ និងស្លាកឈ្មោះ សម្រាប់ពាក់លើឯកសណ្ឋានការងាររបស់មន្ត្រីរាជការស៊ីវិល ដែលបម្រើការងារនៅទីស្តីការក្រសួងមហាផ្ទៃ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានប្រើប្រាស់ទៅតាមប្រភេទក្របខ័ណ្ឌ **ក** ក្របខ័ណ្ឌ **ខ** និងក្របខ័ណ្ឌ **គ** ។

### ផ្នែកទី១
### មួក

**មាត្រា ៨ .―**

មួកសម្រាប់ពាក់ជាមួយឯកសណ្ឋានការងាររបស់មន្ត្រីរាជការស៊ីវិល ដែលបម្រើការងារនៅទីស្តីការក្រសួងមហាផ្ទៃ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានប្រើប្រាស់ទៅតាមឋានន្តរស័ក្តិ នៃប្រភេទក្របខ័ណ្ឌនីមួយៗ ដូចខាងក្រោម ៖

**ក-មួកសម្រាប់ពាក់ចូលរួមក្នុងកិច្ចប្រជុំ សិក្ខាសាលា សន្និបាត និងពិធីផ្សេងៗ ៖ មួកកាស្កេត** ពណ៌ដូចឯកសណ្ឋាន ។ នៅផ្នែកខាងលើមុខមួក មានប៉ាក់ឌិនរូបព្រះសង្ហារពណ៌មាស ពណ៌ប្រាក់ និងពណ៌សំរឹទ្ធ ។ ជាយក្បាំងខាងលើមានរចនាតុបតែងដោយក្បាច់ផ្កាឈូកបីទងនៅចំកណ្តាល និងមានក្បាច់សន្លឹកភ្ញីទេសនៅអមសងខាង ។ នៅជាយក្បាំងខាងលើពីមុខមួក មានខ្សែវណ្ណ័ក្រឡាក្អែប ហើយនៅចុងសងខាងនៃខ្សែវណ្ណក្រឡាក្អែបនេះ មានលំអរដោយឡេវរូបព្រះសង្ហារ ។ ជាយក្បាំងខាងមុខ មានរចនាតុបតែងដោយក្បាច់ផ្កាឈូកបីស្រទាប់ នៅចំកណ្តាល ហើយមានក្បាច់កួរស្រូវ និងក្បាច់សន្លឹកភ្ញីទេសនៅអមសងខាង ។

**ក្របខ័ណ្ឌប្រភេទ ក** ៖ នៅលើក្បាំងមុខនៃមួក មានក្បាច់រចនាពណ៌មាសពេញ សម្គាល់ឋានន្តរស័ក្តិ ក.១ មានក្បាច់រចនា ពីរភាគបី សម្គាល់ឋានន្តរស័ក្តិ ក.២ និងមានក្បាច់រចនាមួយកន្លះ សម្គាល់ឋានន្តរស័ក្តិ ក.៣ ។

**ក្របខ័ណ្ឌប្រភេទ ខ** ៖ នៅលើក្បាំងមុខនៃមួក មានក្បាច់រចនាពណ៌ប្រាក់ពេញ សម្គាល់ឋានន្តរស័ក្តិ ខ.១ មានក្បាច់រចនា ពីរភាគបី សម្គាល់ឋានន្តរស័ក្តិ ខ.២ និងមានក្បាច់រចនាមួយកន្លះ សម្គាល់ឋានន្តរស័ក្តិ ខ.៣ ។

**ក្របខ័ណ្ឌប្រភេទ គ** ៖ នៅលើក្បាំងមុខនៃមួក មានក្បាច់រចនាពណ៌សំរឹទ្ធមួយកន្លះ សម្គាល់ឋានន្តរស័ក្តិនៃក្របខ័ណ្ឌប្រភេទ គ ។

មួកសម្រាប់ពាក់ចូលរួមក្នុងកិច្ចប្រជុំ សិក្ខាសាលា សន្និបាត និងពិធីផ្សេងៗ ដូចមានរូបភាពក្នុងឧបសម្ព័ន្ធទី១៣ ។

**ខ-មួកសម្រាប់ពាក់បំពេញបេសកកម្ម** ៖ មួកកន្តិប ពណ៌ដូចឯកសណ្ឋាន ។ នៅផ្នែកខាងលើមុខមួក មានប៉ាក់រូបព្រះសង្ហារពណ៌មាស ពណ៌ប្រាក់ និងពណ៌សំរឹទ្ធ ។ នៅចំកណ្តាលក្បាំងមួក មានប៉ាក់ក្បាច់ផ្កាឈូកបីទង និងមានក្បាច់សន្លឹកភ្ញីទេសនៅអមសងខាង ។ នៅជាយក្បាំងខាងលើពីមុខមួក មានប៉ាក់ក្បាច់ផ្កាឈូកបីស្រទាប់នៅចំកណ្តាល ហើយមានក្បាច់កួរស្រូវ និងក្បាច់សន្លឹកភ្ញីទេសនៅអមសងខាង ។ នៅជាយក្បាំងមួក មានប៉ាក់ខ្សែវ័ណ្ឌនៅជុំវិញ ។

**ក្របខ័ណ្ឌប្រភេទ ក** ៖ នៅលើក្បាំងមុខនៃមួក មានក្បាច់ និងខ្សែវ័ណ្ឌនៅជុំវិញពណ៌មាសចំនួនបី សម្គាល់ឋានន្តរស័ក្តិ ក.១ ខ្សែវ័ណ្ឌជុំវិញចំនួនពីរ សម្គាល់ឋានន្តរស័ក្តិ ក.២ និងខ្សែវ័ណ្ឌចំនួនមួយ សម្គាល់ឋានន្តរស័ក្តិ ក.៣ ។

**ក្របខ័ណ្ឌប្រភេទ ខ** ៖ នៅលើក្បាំងមុខនៃមួក មានក្បាច់ និងខ្សែវ័ណ្ឌនៅជុំវិញពណ៌ប្រាក់ចំនួនបី សម្គាល់ឋានន្តរស័ក្តិ ខ.១ ខ្សែវ័ណ្ឌជុំវិញចំនួនពីរ សម្គាល់ឋានន្តរស័ក្តិ ខ.២ និងខ្សែវ័ណ្ឌចំនួនមួយ សម្គាល់ឋានន្តរស័ក្តិ ខ.៣ ។

**ក្របខ័ណ្ឌប្រភេទ គ** ៖ នៅលើក្បាំងមុខនៃមួក ផ្នែកខាងលើមុខមួក មានប៉ាក់រូបព្រះសង្ហារពណ៌សំរឹទ្ធ និងនៅចំកណ្តាលក្បាំងមួក មានប៉ាក់ក្បាច់ផ្កាឈូកបីទង អមដោយក្បាច់សន្លឹកភ្ញីទេសពណ៌សំរឹទ្ធ នៅអមសងខាង ។

មួកសម្រាប់ពាក់បំពេញបេសកកម្ម ដូចមានរូបភាពក្នុងឧបសម្ព័ន្ធទី១៤ ។

## ផ្នែកទី២
## សញ្ញាស័ក្តិស្មា

**មាត្រា ៩ .–**

សញ្ញាស័ក្តិស្មា សម្រាប់ពាក់លើស្មាទាំងសងខាង នៃឯកសណ្ឋានការងាររបស់មន្ត្រីរាជការស៊ីវិល ដែលបម្រើការងារនៅទីស្តីការក្រសួងមហាផ្ទៃ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវពាក់ទៅតាមប្រភេទក្របខ័ណ្ឌដូចខាងក្រោម ៖

**១- ក្របខ័ណ្ឌប្រភេទ ក**

សញ្ញាស័ក្តិស្មា មានរូប និងក្បាច់ផ្កាភ្ញីពណ៌មាស ព្រមទាំងមានផ្ទៃ ទម្រង់ និងខ្នាត ដូចមានចែងក្នុងព្រះរាជក្រឹត្យលេខ នស/រកត/០៣០១/០៤៩ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ២០០១ ស្តីពីសញ្ញាស័ក្តិ និងឯកសណ្ឋានមន្ត្រីនៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ និងមន្ត្រីក្រមការរបស់ក្រសួងមហាផ្ទៃ ។

**២- ក្របខ័ណ្ឌប្រភេទ ខ**

សញ្ញាស័ក្តិស្មា មានរូប និងក្បាច់ផ្កាភ្ញីពណ៌ប្រាក់ ព្រមទាំងមានផ្ទៃ ទម្រង់ និងខ្នាត ដូចមានចែងក្នុងព្រះរាជក្រឹត្យលេខ នស/រកត/០៣០១/០៤៩ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ២០០១ ស្តីពីសញ្ញាស័ក្តិ និងឯកសណ្ឋានមន្ត្រីនៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ និងមន្ត្រីក្រមការរបស់ក្រសួងមហាផ្ទៃ ។

**៣- ក្របខ័ណ្ឌប្រភេទ គ**

សញ្ញាស័ក្តិស្មា មានរូប និងក្បាច់ផ្កាភ្ញី ពណ៌សំរឹទ្ធ ព្រមទាំងមានផ្ទៃ ទម្រង់ និងខ្នាត ដូចសញ្ញាស័ក្តិស្មា នៃឋានន្តរស័ក្តិទី៣ នៃក្របខ័ណ្ឌប្រភេទ **ក** ឬក្របខ័ណ្ឌប្រភេទ **ខ** ។

សញ្ញាស័ក្តិស្មា នៃក្របខ័ណ្ឌប្រភេទ **ក** ក្របខ័ណ្ឌប្រភេទ **ខ** និងក្របខ័ណ្ឌប្រភេទ **គ** ខាងលើ ដូចមានរូបភាពក្នុងឧបសម្ព័ន្ធទី១៥ ។

## ផ្នែកទី៣
## សញ្ញាសម្គាល់

**មាត្រា ១០ .—**

សញ្ញាសម្គាល់ សម្រាប់ពាក់ជាមួយឯកសណ្ឋានការងាររបស់មន្ត្រីរាជការស៊ីវិល ដែលបម្រើការងារនៅទីស្តីការក្រសួងមហាផ្ទៃ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវពាក់ទៅតាមប្រភេទក្របខ័ណ្ឌ ដូចខាងក្រោម ៖

**១-រូបសញ្ញាក្រសួងមហាផ្ទៃ នៅចុងកអាវសងខាង** ៖ រូបសញ្ញានេះ ធ្វើឡើងពីលោហៈពណ៌មាស សម្រាប់ក្របខ័ណ្ឌប្រភេទ **ក** ពណ៌ប្រាក់សម្រាប់ក្របខ័ណ្ឌប្រភេទ **ខ** និងពណ៌សំរឹទ្ធ សម្រាប់ក្របខ័ណ្ឌប្រភេទ **គ** ដែលមានទំហំ២៦មីលីម៉ែត្រ និងមានរូបព្រះនារាយណ៍គង់លើបល្ល័ង្កនៅចំកណ្តាលអមដោយគួរស្រូវសងខាង ដូចមានរូបភាពក្នុងឧបសម្ព័ន្ធទី១៦ ។

**២-សញ្ញាសម្គាល់សម្រាប់ដាក់នៅក្រោមស្មាអាវខាងស្តាំ** ៖ សញ្ញាសម្គាល់នេះ ធ្វើឡើងពីក្រណាត់ប៉ាក់រាងមូល មានសញ្ញាសម្គាល់រាងមូលមានរូបទង់ជាតិ នៃព្រះរាជាណាចក្រកម្ពុជា ដែលមានរូបប្រាសាទកំពូលបី នៅចំកណ្តាល ផ្នែកខាងលើសរសេរអក្សរ “ **មន្ត្រីរាជការស៊ីវិល** ” និងផ្នែកខាងក្រោម សរសេរអក្សរឡាតាំង “ CIVIL SERVANT ” ពណ៌ស ព័ទ្ធជុំវិញទៅដោយ ខ្សែពួរវេញពណ៌ស ដែលមានទំហំ២មីលីម៉ែត្រ និងមានអង្កត់ផ្ចិតទំហំ៧៧មីលីម៉ែត្រ ។

**៣-សញ្ញាសម្គាល់សម្រាប់ដាក់នៅក្រោមស្មាអាវខាងឆ្វេង** ៖ សញ្ញាសម្គាល់នេះ ធ្វើឡើងពីក្រណាត់ប៉ាក់ស្លាកអក្សរ “ **ក្រសួងមហាផ្ទៃ** ” ពណ៌ស មានផ្ទៃពណ៌ខៀវចាស់ និងខ្សែវ័ណ្ឌពណ៌ស ដែលមានរាងកោងផ្កាប់ចុះក្រោម មានទំហំ២០មីលីម៉ែត្រ កម្ពស់រាងកោង៤២មីលីម៉ែត្រ ដាក់នៅពីលើ “ **រូបសញ្ញាក្រសួងមហាផ្ទៃ** ” ពណ៌មាស ផ្ទៃពណ៌ស និងមានខ្សែវ័ណ្ឌពណ៌សព័ទ្ធជុំវិញ (សម្រាប់មន្ត្រីរាជការស៊ីវិលនៅទីស្តីការក្រសួងមហាផ្ទៃ) ឬអក្សរ “ **រដ្ឋបាលរាជធានី ខេត្ត...** ” ពណ៌សមានផ្ទៃពណ៌ខៀវចាស់ និងខ្សែវ័ណ្ឌពណ៌ស ដែលមានរាងកោងផ្កាប់ចុះក្រោម ហានទំហំ២០មីលីម៉ែត្រ កម្ពស់ខ្សែកោង៤២មីលីម៉ែត្រ ដាក់នៅពីលើ “ **និមិត្តសញ្ញារដ្ឋបាលរាជធានី ខេត្ត...** ” ដែលមានអង្កត់ផ្ចិតទំហំ៧៧មីលីម៉ែត្រ (សម្រាប់មន្ត្រីរាជការស៊ីវិលនៅរដ្ឋបាលរាជធានី ខេត្ត) ។ សម្រាប់មន្ត្រីរាជការ នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ សញ្ញាសម្គាល់នេះ ធ្វើឡើងពីក្រណាត់ប៉ាក់ស្លាក

អក្សរ " **រាជធានី ខេត្ត...**" ពណ៌ស មានផ្ទៃពណ៌ខៀវចាស់ និងខ្សែវ័ណ្ឌពណ៌ស ដែលមានរាងកោងផ្កាប់ចុះក្រោម មានទំហំ២០មីលីម៉ែត្រ កម្ពស់ខ្សែកោង៤២មីលីម៉ែត្រ ដាក់នៅពីលើ " **និមិត្តសញ្ញារដ្ឋបាលក្រុង ស្រុក ខណ្ឌ...**" ដែលមានអង្កត់ផ្ចិតទំហំ៧៧មីលីម៉ែត្រ (សម្រាប់មន្ត្រីរាជការស៊ីវិលនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ) និងនៅខាងក្រោមមានប៉ាក់ស្លាកអក្សរ " **រដ្ឋបាលក្រុង ស្រុក ខណ្ឌ...** " ពណ៌ស មានផ្ទៃពណ៌ខៀវចាស់ និងខ្សែវ័ណ្ឌពណ៌ស ដែលមានរាងកោងផ្ងារឡើងលើ មានទំហំ២០មីលីម៉ែត្រ កម្ពស់ខ្សែកោង៤២មីលីម៉ែត្រ ។

សញ្ញាសម្គាល់សម្រាប់ដាក់នៅក្រោមស្មាអាវខាងស្តាំ និងសញ្ញាសម្គាល់សម្រាប់ដាក់នៅក្រោមស្មាអាវខាងឆ្វេង ដូចមានរូបភាពក្នុងឧបសម្ព័ន្ធទី១៧ ។

**៤-សញ្ញាសម្គាល់ឋានន្តរស័ក្តិ និងក្របខ័ណ្ឌ** ៖ សម្រាប់ពាក់នៅលើស្លាកឈ្មោះនៃហោប៉ៅអាវខាងស្តាំ ដែលសញ្ញាសម្គាល់នេះ មានទំហំ៦០មីលីម៉ែត្រ ធ្វើឡើងពីលោហៈពណ៌មាស ឬពណ៌ប្រាក់ ឬពណ៌សំរឹទ្ធ ដែលមានរូបនាគនៅចំកណ្តាល អមដោយក្បាច់ភ្ញីទេស និងមានសន្លឹកក្បាច់រចនាបទអង្គរព័ទ្ធជុំវិញ សម្រាប់សម្គាល់ដូចខាងក្រោម :

ក-ក្របខ័ណ្ឌ **ក** ពណ៌មាស ៖

-ឋានន្តរស័ក្តិ **ក.១** មានរូបនាគក្បាលប្រាំពីរនៅចំកណ្តាល អមដោយក្បាច់ភ្ញីទេស និងមានសន្លឹកក្បាច់រចនាបទអង្គរចំនួនបីជាន់ព័ទ្ធជុំវិញ

-ឋានន្តរស័ក្តិ **ក.២** មានរូបនាគក្បាលប្រាំនៅចំកណ្តាល អមដោយក្បាច់ភ្ញីទេស និងមានសន្លឹកក្បាច់រចនាបទអង្គរចំនួនពីរជាន់ព័ទ្ធជុំវិញ

-ឋានន្តរស័ក្តិ **ក.៣** មានរូបនាគក្បាលបីនៅចំកណ្តាល អមដោយក្បាច់ភ្ញីទេស និងមានសន្លឹកក្បាច់រចនាបទអង្គរចំនួនមួយជាន់ព័ទ្ធជុំវិញ ។

ខ-ក្របខ័ណ្ឌ **ខ** ពណ៌ប្រាក់ ៖

-ឋានន្តរស័ក្តិ **ខ.១** មានរូបនាគក្បាលប្រាំពីរនៅចំកណ្តាល អមដោយក្បាច់ភ្ញីទេស និងមានសន្លឹកក្បាច់រចនាបទអង្គរចំនួនបីជាន់ព័ទ្ធជុំវិញ

-ឋានន្តរស័ក្តិ **ខ.២** មានរូបនាគក្បាលប្រាំនៅចំកណ្តាល អមដោយក្បាច់ភ្ញីទេស និងមានសន្លឹកក្បាច់រចនាបទអង្គរចំនួនពីរជាន់ព័ទ្ធជុំវិញ

-ឋានន្តរស័ក្តិ **ខ.៣** មានរូបនាគក្បាលបីនៅចំកណ្តាល អមដោយក្បាច់ភ្ញីទេស និងមានសន្លឹកក្បាច់រចនាបទអង្គរចំនួនមួយជាន់ព័ទ្ធជុំវិញ ។

គ-ក្របខ័ណ្ឌ **គ** ពណ៌សំរឹទ្ធ ៖

-ឋានន្តរស័ក្តិ **គ** មានរូបនាគក្បាលបីនៅចំកណ្តាល អមដោយក្បាច់ភ្ញីទេស និងមានសន្លឹកក្បាច់រចនាបទអង្គរចំនួនមួយជាន់ព័ទ្ធជុំវិញ ។

សញ្ញាសម្គាល់ឋានន្តរស័ក្តិ និងក្របខ័ណ្ឌ សម្រាប់ពាក់នៅលើស្លាកឈ្មោះ នៃហោប៉ៅអាវខាងស្តាំខាងលើ ដូចមានរូបភាពក្នុងឧបសម្ព័ន្ធទី១៨ ។

**៥-សញ្ញាសម្គាល់ពាក់បន្តោកជាមួយខ្សែក្រោមគម្របហោប៉ៅអាវលើខាងស្តាំ** ៖ សម្រាប់សម្គាល់មន្ត្រីរាជការ ដែលទទួលបន្ទុកក្នុងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ នៅអង្គភាពច្រកចេញចូលតែមួយ និងនៅការិយាល័យច្រកចេញចូលតែមួយ ។ សញ្ញាសម្គាល់នេះ មានរាងជារង្វង់មូល

ទំហំ៤៩មីលីម៉ែត្រ ដាក់ពីលើស្បែកបន្ទោកពណ៌ខៀវចាស់ មានរាងជាមេដាយ ដែលមានប្រវែង ១០០មីលីម៉ែត្រ និងមានបាតរាងស្រួច ។ នៅផ្នែកខាងលើក្នុងរង្វង់មូល ដែលមានផ្ទៃពណ៌ស រំលេចដោយអក្សរពណ៌ខៀវថា “ **អង្គភាពច្រកចេញចូលតែមួយ** ” សម្រាប់រដ្ឋបាលរាជធានី ខេត្ត និងអក្សរសរសេរថា “ **ការិយាល័យច្រកចេញចូលតែមួយ** ” សម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ។ នៅផ្នែកខាងក្រោមក្នុងរង្វង់មានដាក់អក្សរជាភាសាអង់គ្លេសថា “One Window Service Office” ។ នៅចន្លោះអក្សរខ្មែរ និងអក្សរអង់គ្លេសខាងលើនេះ មានរូបផ្កាច័ន្ទ ពណ៌ខៀវ ។ នៅចំកណ្ដាលនៃរង្វង់មានរូបសញ្ញាបាតដៃពីរពណ៌ស ទ្រលិខិតដែលមានរំលេចអក្សរថា “ **សេវារហ័ស តម្លាភាព** ” ពណ៌ខៀវ ដែលបង្ហាញអំពីខ្លឹមសារនៃការគាំទ្រពីថ្នាក់ជាតិ ទៅរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្ដល់សេវាសាធារណៈជូនប្រជាពលរដ្ឋដោយឆាប់រហ័ស និងតម្លាភាព ដូចមានរូបភាពក្នុងឧបសម្ព័ន្ធទី១៩ ។

## ផ្នែកទី៤
## ស្លាកឈ្មោះ

**មាត្រា ១១ .–**

ស្លាកឈ្មោះសម្រាប់ពាក់នៅលើហោប៉ៅអាវខាងស្ដាំ មានរាងបួនជ្រុងទ្រវែង បណ្ដោយប្រវែង៨៩មីលីម៉ែត្រ និងទទឹងប្រវែង២០មីលីម៉ែត្រ ធ្វើអំពីលោហៈភ្ជាប់ជ័រឹងថ្លា ផ្ទៃពណ៌ខៀវចាស់ និងមានខ្សែវណ្ឌពណ៌មាស ទំហំ២.៥មីលីម៉ែត្រព័ទ្ធជុំវិញ ។ នៅខាងស្ដាំ នៃស្លាកឈ្មោះ មានរូបសញ្ញាក្រសួងមហាផ្ទៃរាងមូលពណ៌មាស ដែលមានអង្កត់ផ្ចិត១៣មីលីម៉ែត្រ (សម្រាប់មន្ត្រីរាជការនៅទីស្ដីការក្រសួងមហាផ្ទៃ) ឬនិមិត្តសញ្ញារដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ រាងមូល ដែលមានអង្កត់ផ្ចិត១៣មីលីម៉ែត្រ (សម្រាប់មន្ត្រីរាជការនៅរដ្ឋបាលថ្នាក់ក្រោមជាតិ) ។ ផ្នែកខាងឆ្វេងនៃស្លាកឈ្មោះ នៅជួរខាងលើ មានសរសេរនាមត្រកូល និងនាមខ្លួនជាអក្សរយូនីកូដខ្មែរមូល ( Khmer Mool 1 ) ពណ៌មាស ទំហំ១៨ ឬអាចមានទំហំអក្សរប្រែប្រួលតាមនាមត្រកូល និងនាមខ្លួនរបស់មន្ត្រីរាជការ ។ នៅជួរកណ្ដាល មានសរសេរមុខតំណែងរបស់មន្ត្រីរាជការម្នាក់ៗ ជាអក្សរយូនីកូដខ្មែរមូល (Khmer Mool 1) ពណ៌មាស ទំហំ១២ និងនៅផ្នែកខាងក្រោម មានសរសេរអត្តលេខមន្ត្រីម្នាក់ៗ ជាអក្សរឡាតាំង (Times New Roman) ពណ៌មាសទំហំ១២ ដូចមានរូបភាពក្នុងឧបសម្ព័ន្ធទី២០ ។

# ជំពូកទី៤
# របបផ្គត់ផ្គង់ និងការប្រើប្រាស់ឯកសណ្ឋាន

## ផ្នែកទី១
## របបផ្គត់ផ្គង់ឯកសណ្ឋាន

**មាត្រា ១២ .–**

មន្ត្រីរាជការស៊ីវិលនៅទីស្ដីការក្រសួងមហាផ្ទៃ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលបាននូវរបបឯកសណ្ឋាន ដូចបានកំណត់ក្នុងអនុក្រឹត្យនេះ ជារៀងរាល់ឆ្នាំ ស្របតាមទំហំនៃថវិកាជាតិប្រចាំឆ្នាំ ដែលបានវិភាជជូនក្រសួងមហាផ្ទៃ និងថវិកាផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ។

## ផ្នែកទី២
## ការប្រើប្រាស់ឯកសណ្ឋាន

**មាត្រា ១៣ .-**

ឯកសណ្ឋានការងារសម្រាប់មន្ត្រីរាជការស៊ីវិលនៅទីស្តីការក្រសួងមហាផ្ទៃ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានកំណត់ការប្រើប្រាស់ ដូចខាងក្រោម ៖

- ឯកសណ្ឋានសម្រាប់មន្ត្រីក្របខ័ណ្ឌប្រភេទ **ក** ក្របខ័ណ្ឌប្រភេទ **ខ** និងក្របខ័ណ្ឌប្រភេទ **គ** ដែលត្រូវប្រើប្រាស់ក្នុងការបំពេញការងារប្រចាំថ្ងៃ និងក្នុងពេលចុះបំពេញបេសកកម្ម ដូចមានរូបភាពក្នុងឧបសម្ព័ន្ធទី២១ ។
- ឯកសណ្ឋានសម្រាប់មន្ត្រីក្របខ័ណ្ឌប្រភេទ **ក** ក្របខ័ណ្ឌប្រភេទ **ខ** និងក្របខ័ណ្ឌប្រភេទ **គ** ដែលត្រូវប្រើប្រាស់ក្នុងកិច្ចប្រជុំ សិក្ខាសាលា សន្និបាត និងពិធីនានា ដូចមានរូបភាពក្នុងឧបសម្ព័ន្ធទី២២ ។
- ចំពោះឯកសណ្ឋានមន្ត្រីរាជការដែលបម្រើការងារនៅអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត និងការិយាល័យច្រកចេញចូលតែមួយក្រុង ស្រុក ខណ្ឌ ត្រូវបំពាក់បន្ថែកសញ្ញាសម្គាល់សម្រាប់មន្ត្រីរាជការ ដែលទទួលបន្ទុកក្នុងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ ជាមួយខ្សែក្រោមគម្រប ហោប៉ៅអាវលើខាងស្តាំ លើឯកសណ្ឋានក្នុងការបំពេញការងារប្រចាំថ្ងៃ កិច្ចប្រជុំ សិក្ខាសាលា សន្និបាត ពិធីនានា និងក្នុងការបំពេញបេសកកម្មនានា ។

ចំពោះមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបំពេញការងារតាមវិស័យជំនាញនានា ដែលបានផ្ទេរមុខងារឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ អាចបន្តប្រើប្រាស់ឯកសណ្ឋាន ដែលបានកំណត់តាមវិស័យជំនាញនីមួយៗបាន ។

## ជំពូកទី៥
## ទោសប្បញ្ញត្តិ

**មាត្រា ១៤ .-**

ជនណាដែលបានស្លៀកពាក់ក្លែងបន្លំឯកសណ្ឋានការងារ មួក សញ្ញាស័ក្តិស្មា សញ្ញាសម្គាល់ និងស្លាកឈ្មោះរបស់មន្ត្រីរាជការស៊ីវិល ដែលបម្រើការងារនៅទីស្តីការក្រសួងមហាផ្ទៃ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

## ជំពូកទី៦
## អន្តរប្បញ្ញត្តិ

**មាត្រា ១៥ .-**

មន្ត្រីរាជការស៊ីវិល ដែលបម្រើការងារនៅទីស្តីការក្រសួងមហាផ្ទៃ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ អាចប្រើប្រាស់ឯកសណ្ឋានផ្ទាល់ខ្លួន សម្រាប់មកបំពេញការងាររហូតដល់ទទួលបានរបបឯកសណ្ឋាន តាមគោលការណ៍កំណត់ ។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**មាត្រា ១៦ .—**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៧ .—**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃព្រហស្បតិ៍ ១២កើត ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធទី១

នៃអនុក្រឹត្យលេខ១៤១...... អនក្រ.បក ចុះថ្ងៃទី២៨..... ខែមិថុនា.. ឆ្នាំ២០២៣
ស្តីពីឯកសណ្ឋានបំពេញការងាររបស់មន្ត្រីរាជការស៊ីវិលនៅទីស្តីការក្រសួងមហាផ្ទៃ
និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

## គំរូឯកសណ្ឋានការងារសម្រាប់មន្ត្រីក្របខ័ណ្ឌប្រភេទ ក

### ១-ចំពោះបុរស

ក-អាវសម្រាប់បំពេញការងារប្រចាំថ្ងៃ និងបេសកកម្ម ៖









## ឧបសម្ព័ន្ធទី២

នៃអនុក្រឹត្យលេខ ............ អនក្រ.បក ចុះថ្ងៃទី............ ខែ............ ឆ្នាំ២០២៣
ស្តីពីឯកសណ្ឋានបំពេញការងាររបស់មន្ត្រីរាជការស៊ីវិលនៅទីស្តីការក្រសួងមហាផ្ទៃ
និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

### គំរូឯកសណ្ឋានការងារសម្រាប់មន្ត្រីក្របខ័ណ្ឌប្រភេទ ក

**១-ចំពោះបុរស**

ក-អាវសម្រាប់ចូលរួមកិច្ចប្រជុំ សិក្ខាសាលា សន្និបាត និងពិធីផ្សេងៗ៖









## ឧបសម្ព័ន្ធទី៣

នៃអនុក្រឹត្យលេខ ១៨៤១...... អនក្រ.បក ចុះថ្ងៃទី ២៨...... ខែមិថុនា ឆ្នាំ២០២៣
ស្តីពីឯកសណ្ឋានបំពេញការងាររបស់មន្ត្រីរាជការស៊ីវិលនៅទីស្តីការក្រសួងមហាផ្ទៃ
និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

**គំរូឯកសណ្ឋានការងារសម្រាប់មន្ត្រីក្របខ័ណ្ឌប្រភេទ ក**

**២-ចំពោះស្ត្រី**

**ក- អាវសម្រាប់បំពេញការងារប្រចាំថ្ងៃ និងបេសកកម្ម ៖**

**ការងារប្រចាំថ្ងៃ** **បេសកកម្ម**









## ឧបសម្ព័ន្ធទី៤

នៃអនុក្រឹត្យលេខ .............. អនក្រ.បក ចុះថ្ងៃទី .......... ខែ .......... ឆ្នាំ២០២៣
ស្តីពីឯកសណ្ឋានបំពេញការងាររបស់មន្ត្រីរាជការស៊ីវិលនៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ... 

**គំរូឯកសណ្ឋានការងារសម្រាប់មន្ត្រីក្របខ័ណ្ឌប្រភេទ ក**

**២-ចំពោះស្ត្រី**

**ក- អាវសម្រាប់ចូលរួមកិច្ចប្រជុំ សិក្ខាសាលា សន្និបាត និងពិធីផ្សេងៗ ៖**








# ឧបសម្ព័ន្ធទី៥

នៃអនុក្រឹត្យលេខ ១៤១ ....... អនក្រ.បក ចុះថ្ងៃទី ២៥ ..... ខែ សីហា ឆ្នាំ២០២៣
ស្ដីពីឯកសណ្ឋានបំពេញការងាររបស់មន្ត្រីរាជការស៊ីវិលនៅទីស្ដីការក្រសួងមហាផ្ទៃ
និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

## គំរូឯកសណ្ឋានការងារសម្រាប់មន្ត្រីក្របខ័ណ្ឌប្រភេទ ខ

**១-ចំពោះបុរស**

ក-អាវសម្រាប់បំពេញការងារប្រចាំថ្ងៃ និងបំពេញបេសកកម្ម ៖










# ឧបសម្ព័ន្ធទី៦

នៃអនុក្រឹត្យលេខ ១៤១...... អនក្រ.បក ចុះថ្ងៃទី ២៨..... ខែ មិថុនា.. ឆ្នាំ២០២៣
ស្ដីពីឯកសណ្ឋានបំពេញការងាររបស់មន្ត្រីរាជការស៊ីវិលនៅទីស្ដីការក្រសួងមហាផ្ទៃ
និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

## គំរូឯកសណ្ឋានការងារសម្រាប់មន្ត្រីក្របខ័ណ្ឌប្រភេទ ខ

**១-ចំពោះបុរស**

ក-អាវសម្រាប់ចូលរួមកិច្ចប្រជុំ សិក្ខាសាលា សន្និបាត និងពិធីផ្សេងៗ ៖










# ឧបសម្ព័ន្ធទី៧

នៃអនុក្រឹត្យលេខ ............ អនក្រ.បក ចុះថ្ងៃទី ........ ខែ ........ ឆ្នាំ២០២៣
ស្តីពីឯកសណ្ឋានបំពេញការងាររបស់មន្ត្រីរាជការស៊ីវិលនៅទីស្តីការក្រសួងមហាផ្ទៃ
និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

## គំរូឯកសណ្ឋានការងារសម្រាប់មន្ត្រីក្របខ័ណ្ឌប្រភេទ ខ

**២-ចំពោះស្ត្រី**

ក- អាវសម្រាប់បំពេញការងារប្រចាំថ្ងៃ និងបេសកកម្ម ៖

ការងារប្រចាំថ្ងៃ បេសកកម្ម









# ឧបសម្ព័ន្ធទី៨

នៃអនុក្រឹត្យលេខ .................. អនក្រ.បក ចុះថ្ងៃទី .......... ខែ .......... ឆ្នាំ២០២៣
ស្តីពីឯកសណ្ឋានបំពេញការងាររបស់មន្ត្រីរាជការស៊ីវិលនៅទីស្តីការក្រសួងមហាផ្ទៃ
និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

## គំរូឯកសណ្ឋានការងារសម្រាប់មន្ត្រីក្របខ័ណ្ឌប្រភេទ ខ

### ២-ចំពោះស្ត្រី

ក- អាវសម្រាប់ចូលរួមកិច្ចប្រជុំ សិក្ខាសាលា សន្និបាត និងពិធីផ្សេងៗ ៖








# ឧបសម្ព័ន្ធទី៩

នៃអនុក្រឹត្យលេខ ............ អនក្រ.បក ចុះថ្ងៃទី ......... ខែ ......... ឆ្នាំ២០២៣
ស្តីពីឯកសណ្ឋានបំពេញការងាររបស់មន្ត្រីរាជការស៊ីវិលនៅទីស្តីការក្រសួងមហាផ្ទៃ
និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

## គំរូឯកសណ្ឋានការងារសម្រាប់មន្ត្រីក្របខ័ណ្ឌប្រភេទ ឥ

### ១-ចំពោះបុរស

ក-អាវសម្រាប់បំពេញការងារប្រចាំថ្ងៃ និងបេសកកម្ម ៖










# ឧបសម្ព័ន្ធទី១០

នៃអនុក្រឹត្យលេខ .............. អនក្រ.បក ចុះថ្ងៃទី .......... ខែ .......... ឆ្នាំ២០២៣
ស្តីពីឯកសណ្ឋានបំពេញការងាររបស់មន្ត្រីរាជការស៊ីវិលនៅទីស្តីការក្រសួងមហាផ្ទៃ
និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

## គំរូឯកសណ្ឋានការងារសម្រាប់មន្ត្រីក្របខ័ណ្ឌប្រភេទ ឥ

**១-ចំពោះបុរស**

ក-អាវសម្រាប់ចូលរួមកិច្ចប្រជុំ សិក្ខាសាលា សន្និបាត និងពិធីផ្សេងៗ ៖









## ឧបសម្ព័ន្ធទី១១

នៃអនុក្រឹត្យលេខ ...១៤១...... អនក្រ.បក ចុះថ្ងៃទី ...២៦.... ខែ មិថុនា ឆ្នាំ២០២៣
ស្តីពីឯកសណ្ឋានបំពេញការងាររបស់មន្ត្រីរាជការស៊ីវិលនៅទីស្តីការក្រសួងមហាផ្ទៃ
និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

### គំរូឯកសណ្ឋានការងារសម្រាប់មន្ត្រីក្របខ័ណ្ឌប្រភេទ គ

**២-ចំពោះស្ត្រី**

ក- អាវសម្រាប់បំពេញការងារប្រចាំថ្ងៃ និងបេសកកម្ម ៖

**ការងារប្រចាំថ្ងៃ** **បេសកកម្ម**











# ឧបសម្ព័ន្ធទី១២

នៃអនុក្រឹត្យលេខ ១៤១ អនក្រ.បក ចុះថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ២០២៣
ស្តីពីឯកសណ្ឋានបំពេញការងាររបស់មន្ត្រីរាជការស៊ីវិលនៅទីស្តីការក្រសួងមហាផ្ទៃ
និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

## គំរូឯកសណ្ឋានភារខោអាវសម្រាប់មន្ត្រីក្របខ័ណ្ឌប្រភេទ គ

**២-ចំពោះស្ត្រី**

ក- អាវសម្រាប់ចូលរួមកិច្ចប្រជុំ សិក្ខាសាលា សន្និបាត និងពិធីផ្សេងៗ ៖








# ឧបសម្ព័ន្ធទី១៣

នៃអនុក្រឹត្យលេខ ..១..៤..១..... អនក្រ.បក ចុះថ្ងៃទី ..២..៩..... ខែ ..មិថុនា.. ឆ្នាំ២០២៣
ស្តីពីឯកសណ្ឋានបំពេញការងាររបស់មន្ត្រីរាជការស៊ីវិលនៅទីស្តីការក្រសួងមហាផ្ទៃ
និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

## គំរូ មួកកាស្កេត សម្រាប់មន្ត្រីរាជការក្របខ័ណ្ឌប្រភេទ ក


ឋានន្តរស័ក្តិ ក-១


ឋានន្តរស័ក្តិ ក-២


ឋានន្តរស័ក្តិ ក-៣

## គំរូ មួកកាស្កេត សម្រាប់មន្ត្រីរាជការក្របខ័ណ្ឌប្រភេទ ខ


ឋានន្តរស័ក្តិ ខ-១


ឋានន្តរស័ក្តិ ខ-២


ឋានន្តរស័ក្តិ ខ-៣

## គំរូ មួកកាស្កេត សម្រាប់មន្ត្រីរាជការក្របខ័ណ្ឌប្រភេទ គ


ឋានន្តរស័ក្តិ គ

## ឧបសម្ព័ន្ធទី១៤

នៃអនុក្រឹត្យលេខ ១៤១ អនក្រ.បក ចុះថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ២០២៣
ស្តីពីឯកសណ្ឋានបំពេញការងាររបស់មន្ត្រីរាជការស៊ីវិលនៅទីស្តីការក្រសួងមហាផ្ទៃ
និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

### គំរូ មួកកន្តិប សម្រាប់មន្ត្រីរាជការក្របខ័ណ្ឌប្រភេទ ក


ឋានន្តរស័ក្តិ ក-១


ឋានន្តរស័ក្តិ ក-២


ឋានន្តរស័ក្តិ ក-៣

### គំរូ មួកកន្តិប សម្រាប់មន្ត្រីរាជការក្របខ័ណ្ឌប្រភេទ ខ


ឋានន្តរស័ក្តិ ខ-១


ឋានន្តរស័ក្តិ ខ-២


ឋានន្តរស័ក្តិ ខ-៣

### គំរូ មួកកន្តិប សម្រាប់មន្ត្រីរាជការក្របខ័ណ្ឌប្រភេទ គ


ឋានន្តរស័ក្តិ គ

# ឧបសម្ព័ន្ធទី១៥

នៃអនុក្រឹត្យលេខ ១៤១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ២០២៣
ស្តីពីឯកសណ្ឋានបំពេញការងាររបស់មន្ត្រីរាជការស៊ីវិលនៅទីស្តីការក្រសួងមហាផ្ទៃ
និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

## គំរូ សញ្ញាស័ក្តិស្មា សម្រាប់មន្ត្រីរាជការក្របខ័ណ្ឌប្រភេទ ក ពណ៌មាស



ឋានន្តរស័ក្តិ ក-១




ឋានន្តរស័ក្តិ ក-២




ឋានន្តរស័ក្តិ ក-៣

## គំរូ សញ្ញាស័ក្តិស្មា សម្រាប់មន្ត្រីរាជការក្របខ័ណ្ឌប្រភេទ ខ ពណ៌ប្រាក់




ឋានន្តរស័ក្តិ ខ-១




ឋានន្តរស័ក្តិ ខ-២




ឋានន្តរស័ក្តិ ខ-៣

## គំរូ សញ្ញាស័ក្តិស្មា សម្រាប់មន្ត្រីរាជការក្របខ័ណ្ឌប្រភេទ គ ពណ៌សំរិទ្ធ



ឋានន្តរស័ក្តិ គ

## ឧបសម្ព័ន្ធទី១៦

នៃអនុក្រឹត្យលេខ១៤៣២...... អនក្រ.បក ចុះថ្ងៃទី ២៩.... ខែមិថុនា. ឆ្នាំ២០២៣
ស្តីពីឯកសណ្ឋានបំពេញការងាររបស់មន្ត្រីរាជការស៊ីវិលនៅទីស្តីការក្រសួងមហាផ្ទៃ
និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

**គំរូ សញ្ញាសម្គាល់ ចុង ក អាវ សម្រាប់ក្របខ័ណ្ឌប្រភេទ ក ពណ៌មាស**



**គំរូ សញ្ញាសម្គាល់ ចុង ក អាវ សម្រាប់ក្របខ័ណ្ឌប្រភេទ ខ ពណ៌ប្រាក់**



**គំរូ សញ្ញាសម្គាល់ ចុង ក អាវ សម្រាប់ក្របខ័ណ្ឌប្រភេទ គ ពណ៌សំរិទ្ធ**



# ឧបសម្ព័ន្ធទី១៧

នៃអនុក្រឹត្យលេខ១៤១...... អនក្រ.បក ចុះថ្ងៃទី៤កើត..... ខែភទ្របទ ឆ្នាំ២០២៣
ស្តីពីឯកសណ្ឋានបំពេញការងាររបស់មន្ត្រីរាជការស៊ីវិលនៅទីស្តីការក្រសួងមហាផ្ទៃ
និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

## គំរូ សញ្ញាសម្គាល់សម្រាប់ដាក់នៅក្រោមស្មារអាវខាងស្តាំ




## គំរូ សញ្ញាសម្គាល់សម្រាប់ដាក់នៅក្រោមស្មារអាវខាងឆ្វេង



## ឧបសម្ព័ន្ធទី១៨

នៃអនុក្រឹត្យលេខ ១៤០១ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ២០២៣
ស្តីពីឯកសណ្ឋានបំពេញការងាររបស់មន្ត្រីរាជការស៊ីវិលនៅទីស្តីការក្រសួងមហាផ្ទៃ
និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

### គំរូ សញ្ញាសម្គាល់ឋានន្តរស័ក្តិ និងក្រុបខ័ណ្ឌ ប្រភេទ ក ពណ៌មាស



ឋានន្តរស័ក្តិ ក-១



ឋានន្តរស័ក្តិ ក-២



ឋានន្តរស័ក្តិ ក-៣

### គំរូ សញ្ញាសម្គាល់ឋានន្តរស័ក្តិ និងក្រុបខ័ណ្ឌ ប្រភេទ ខ ពណ៌ប្រាក់



ឋានន្តរស័ក្តិ ខ-១



ឋានន្តរស័ក្តិ ខ-២



ឋានន្តរស័ក្តិ ខ-៣

### គំរូ សញ្ញាសម្គាល់ឋានន្តរស័ក្តិ និងក្រុបខ័ណ្ឌ ប្រភេទ គ ពណ៌សំរិទ្ធ



ឋានន្តរស័ក្តិ គ

## ឧបសម្ព័ន្ធទី១៩

នៃអនុក្រឹត្យលេខ...១៤១...... អនក្រ.បក ចុះថ្ងៃទី...២៩.... ខែ...សីហា... ឆ្នាំ២០២៣
ស្តីពីឯកសណ្ឋានបំពេញការងាររបស់មន្ត្រីរាជការស៊ីវិលនៅទីស្តីការក្រសួងមហាផ្ទៃ
និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

### គំរូ សញ្ញាសម្គាល់អង្គភាពច្រកចេញចូលតែមួយ

### រដ្ឋបាលរាជធានី ខេត្ត




### គំរូ សញ្ញាសម្គាល់ការិយាល័យច្រកចេញចូលតែមួយ

### រដ្ឋបាលក្រុង ស្រុក ខណ្ឌ



## ឧបសម្ព័ន្ធទី២០

នៃអនុក្រឹត្យលេខ ១៤១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ២០២៣
ស្តីពីឯកសណ្ឋានបំពេញការងាររបស់មន្ត្រីរាជការស៊ីវិលនៅទីស្តីការក្រសួងមហាផ្ទៃ
និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

**គំរូ ស្លាកឈ្មោះ សម្រាប់ក្របខ័ណ្ឌប្រភេទ ក ប្រភេទ ខ និងប្រភេទ គ**

**រដ្ឋបាលថ្នាក់ជាតិ**




**រដ្ឋបាលថ្នាក់ក្រោមជាតិ**



## ឧបសម្ព័ន្ធទី២១

នៃអនុក្រឹត្យលេខ ១៤១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែសីហា ឆ្នាំ២០២៣
ស្តីពីឯកសណ្ឋានបំពេញការងាររបស់មន្ត្រីរាជការស៊ីវិលនៅទីស្តីការក្រសួងមហាផ្ទៃ
និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

## គំរូឯកសណ្ឋានការងាររបស់មន្ត្រីរាជការស៊ីវិលនៅទីស្តីការក្រសួងមហាផ្ទៃ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

### ក-ឯកសណ្ឋានសម្រាប់បំពេញការងារប្រចាំថ្ងៃ

**ក្របខ័ណ្ឌប្រភេទ ក**



គ្របខ័ណ្ឌប្រភេទ ក



ក្របខ័ណ្ឌប្រភេទ ២



គ្រឿងឯកសណ្ឋានប្រភេទ ១



ក្របខ័ណ្ឌប្រភេទ ក



ក្របខ័ណ្ឌប្រភេទ ឥ



## ខ-ឯកសណ្ឋានសម្រាប់បំពេញបេសកកម្ម

ក្រុមខ័ណ្ឌប្រភេទ ក



ក្របខ័ណ្ឌប្រភេទ ទ



គ្របខ័ណ្ឌប្រភេទ **ខ**



ក្របខ័ណ្ឌប្រភេទ ខ



**ក្របខ័ណ្ឌប្រភេទ ឥ**



គ្របខណ្ឌប្រភេទ **គ**



# ឧបសម្ព័ន្ធទី២២

នៃអនុក្រឹត្យលេខ .................. អនក្រ.បក ចុះថ្ងៃទី ........... ខែ ........... ឆ្នាំ២០២៣
ស្តីពីឯកសណ្ឋានបំពេញការងាររបស់មន្ត្រីរាជការស៊ីវិលនៅទីស្តីការក្រសួងមហាផ្ទៃ
និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

## គំរូឯកសណ្ឋានការងាររបស់មន្ត្រីរាជការស៊ីវិលនៅទីស្តីការក្រសួងមហាផ្ទៃ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

**ក-ឯកសណ្ឋានសម្រាប់ចូលរួមកិច្ចប្រជុំ សិក្ខាសាលា សន្និបាត និងពិធីផ្សេងៗ**

**ក្របខ័ណ្ឌប្រភេទ ក**



គ្រុបខ័ណ្ឌប្រភេទ ឥ



ក្របខ័ណ្ឌប្រភេទ ២



ក្របខ័ណ្ឌប្រភេទ ២



ក្របខ័ណ្ឌប្រភេទ គ



ក្របខ័ណ្ឌប្រភេទ ឥ

